**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការប្រើប្រាស់ដីក្នុង ឃុំសាមគ្គី

## ឆ្នាំ ២០០៩-២០២២

## ស្រុកអូរជុំ ខេត្តរតនគិរី



**រៀបចំដោយៈ** គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

**គាំទ្រដោយៈ** ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

**ខែ ធ្នូ ឆ្នាំ ២០០៩**

# មាតិកា


**អារម្ភកថា** ០៣

**សេចក្តីផ្តើម** ០៥

**ជំពូក១ : ព័ត៌មាន និងទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ** ០៦

១.១ ស្ថានភាពទូទៅ ០៦

១.១.១ ទីតាំងរដ្ឋបាល ០៦

១.១.២ ប្រជាសាស្ត្រ ០៧

១.១.៣ ភាពគ្មានដីធ្លី ០៨

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ០៩

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ០៩

១.១.៦ ស្ថានភាពសុខាភិបាល ១០

១.១.៦.១ ផ្នែកសុខាភិបាល ១០

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ១២

១.២ ស្ថានភាពភូមិសាស្ត្រ ១២

១.២.១ ទីតាំងភូមិសាស្ត្រ ១២

១.២.២ អាកាសធាតុ ១៣

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ១៣

១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន ១៤

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ១៤

១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី ១៥

១.៣.៣ ស្ថានភាពកសិកម្ម ១៦

១.៣.៤ ធនធានធម្មជាតិ ១៧

១.៣.៤.១ ធនធានព្រៃឈើ ១៧

១.៣.៤.២ ធនធានជលផល ១៨

១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល ១៨

១.៤.១ ទីផ្សារ និងតំលៃកសិផល ផល-អនុផលព្រៃឈើ និងផលនេសាទ ១៨

១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ១៩

១.៤.៣ ឱកាស និងឧបស័គ្គ ១៩
**ជំពូក២ : ការវិភាគតំរូវការសំរាប់អនាគត** ២០
២.១ តំបន់រសើប ២០
២.២ ការប្រឈម/ ឧបស័គ្គ ២០
២.៣ តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំឯកភាព ២១
២.៤ តំរូវការដីសំរាប់អនាគត ២១
២.៤.១ ប្រជាសាស្ត្រ ២១
២.៤.១.១ អត្រាកំណើន ២១
២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ២២
២.៤.២ តំរូវការដីសំរាប់លំនៅដ្ឋាន ២២
២.៤.៣ តំរូវការដីកសិកម្ម ២៣
២.៤.៤ តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ២៤
២.៤.៥ តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ២៤
២.៤.៥.១ តម្រូវការសាលារៀន ២៤
២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ២៥
ក.សេវាកម្មសុខភាព ២៥
ខ.ការផ្គត់ផ្គង់ទឹកស្អាត ២៦
២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា ២៦
២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព ៣៦
**ជំពូក៣ : ផែនការប្រើប្រាស់ដីពេលអនាគត ឆ្នាំ២០០៩ ដល់ ២០២២** ២៧
៣.១ ស្ថានភាពដី សក្តានុពលដី និងតំរូវការដី ២៧
៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ២៧
៣.១.២ តំរូវការដីតាមប្រភេទ ២៧
៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់ ២៨
៣.២.១ ការវិភាគអន្តរអំពើ ២៨
៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត ២៩
៣.២.៣ ការបរិយាយការប្រើប្រាស់ដីតាមក្បាលដី ៣០

# អារម្ភកថា

របាយការណ៍ស្តីអំពីផែនការប្រើប្រាស់ដីនៅក្នុងឃុំសាមគ្គីឆ្នាំ២០២២ត្រូវបានរៀបចំឡើង ដោយក្រុមប្រឹក្សាឃុំសាមគ្គី និងមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈដោយមានការចូលរួមជួយពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី (D_LUP) ស្រុកអូរជុំសហការចូលរួមសម្របសម្រួលពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី ( P_LUP ) ខេត្តរតនគិរី និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី ( Land Management Component )របស់អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពី អង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូត ដាណឺម៉ាក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។គោលបំណងចម្បងនៃផែនការប្រើប្រាស់ដី នៅក្នុងឃុំសាមគ្គីនេះ គឺដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំកម្មវិធីវិនិយោគឃុំ និងសំរាប់ប្រើប្រាស់ក្នុងការរៀបចំអភិវឌ្ឍន៍ឃុំទាំងមូល ឱ្យមាននិរន្តរភាព ចំទិសដៅ និង ឱ្យស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយ វិមជ្ឈការ និង វិសហមជ្ឈការ សំដៅពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល ដើម្បីលើកស្ទួយសេដ្ឋកិច្ច និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ។

ក្រុមប្រឹក្សាឃុំសាមគ្គី សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និងអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាក ប្រចាំនៅក្នុងប្រទេសកម្ពុជាដែលបានផ្តល់ថវិកាជំនួយ សំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីនេះចាប់តាំងពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់ ។

ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណផងដែរដល់ក្រុមការងាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តរតនគិរី ដែលបានជួយសម្របសម្រួលក្នុងការរៀបចំផែនការនេះ ហើយផែនការប្រើប្រាស់ដីដែលបានលេចចេញជារូបរាងប្រកបដោយជោគជ័យនេះ ក៏ដោយសារតែមានការចូលរួម និងគាំទ្រពីសំណាក់មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ជាពិសេសគឺអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត រដ្ឋបាលព្រៃឈើ មន្ទីរកសិកម្ម និងមន្ទីរបរិស្ថានខេត្ត ។

ក្រុមប្រឹក្សាឃុំសាមគ្គី ក៏មិនអាចបំភ្លេចបានផងដែរនូវការជួយឧបត្ថម្ភគាំទ្រ បង្ហាត់បង្ហាញទាំងទ្រឹស្តី និងបច្ចេកទេស អនុវត្តផ្ទាល់លើការងាររៀបចំផែនការប្រើប្រាស់ដីធ្លី ពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត ( P_LUP ) ថ្នាក់ស្រុក (D_LUP) និងក្រុមការងារថ្នាក់ជាតិ របស់សមាសភាគរៀបចំដែនដី ។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់នឹងបានយល់ដឹងអំពី ស្ថានភាព និងតម្រូវការ ព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី ដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ឃុំសាមគ្គីហើយ នឹងបង្ហាញនូវទឹកចិត្តសម្បុរសធម៌ដ៏ថ្លៃថ្លាតាមរយៈការចូលរួម ផ្តល់នូវ

សំភារៈ និង ថវិការសំរាប់គាំទ្រការអនុវត្តន៏ផែនការប្រើប្រាស់ដីធ្លីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៏ មូលដ្ឋានតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ។

ឃុំសាមគ្គី,ថ្ងៃទី...02...ខែ...04.......ឆ្នាំ ២០10

មេឃុំ សាមគ្គី

# សេចក្តីផ្តើម

ឃុំសាមគ្គី ស្រុកអូរជុំ ខេត្តរតនគិរី ស្ថិតនៅប៉ែកខាងកើតនៃទីរួមស្រុកអូរជុំ ដែលមានទីតាំងនៅភូមិញ៉ុក មានចំងាយ ១៨ គីឡូម៉ែត្រ ពីសាលាស្រុកអូរជុំ និងស្ថិតនៅភាគខាងជើងឈៀងខាងកើត នៃទីរួមខេត្តរតនគិរី មាន ចំងាយ ៨៦ គីឡូម៉ែត្រពីទីរួមខេត្តដែលមានព្រំប្រទល់ឃុំ ខាងកើតទល់ នឹងឃុំកិះចុង ស្រុកបរកែវខាងលិចទល់នឹង ឃុំល្អក់ ខាងជើងទល់ នឹងឃុំប៉ូយ និង ខាងត្បូងទល់ នឹងឃុំឯកភាព ។ ឃុំមានលក្ខណៈភូមិសាស្រ្ត ប្រជាជនទូទៅ ប្រកបមុខរបរធ្វើចំការដោយស្ថានភាពអំណោយផលឃុំសាមគ្គី ដូចជាតំបន់ខ្ពង់រាបដែលពុំមាន ទន្លេ ស្ទឹង ឬព្រែកអ្វី ឡើយ។ ភាគច្រើនប្រកបមុខរបរធ្វើចំការ ប៉ុន្តែឃុំនេះសំបូរទៅដោយអូរធម្មជាតិតូចៗ ជាច្រើនផងដែរ ដែលជា លក្ខណះអំណោយផលរបស់ធម្មជាតិ។ អ្នកភូមិអាចរកត្រី ក្តាម ខ្យងកង្កែប អណ្តើក កំពឹស បានខ្លះៗ តាមដងអូរទាំង។ ដោយស្ថានភាពអំណោយផល ឃុំសាមគ្គីភាគច្រើនប្រជាជនបកបមុខរបរធ្វើចំការ និងដាំកូនឈើ ដំណាំហូបផ្លែ ដំណាំ ផ្សេងៗ និងការចញ្ចឹមសត្វ រកអនុផលព្រៃឈើជាដើម ។ ដោយពិនិត្យឃើញថាឃុំសាមគ្គី មិនទាន់មានការគ្រប់គ្រងដី និង ធនធានធម្មជាតិពុំទាន់ច្បាស់លាស់ជាហេតុធ្វើអោយក្រុមប្រឹក្សាឃុំ និងសមាជិក គ.ផ.ថ ប្រជាជនក្នុងឃុំមាន គោលបំណងបង្កើតផែនការប្រើប្រាស់ដីឃុំមួយប្រកបដោយចីរភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់។ ផែនការប្រើប្រាស់ ដី បើនិយាយជារួមបានឆ្លុះបញ្ចាំងពីបញ្ហា និង តំរូវការចាំបាច់របស់ប្រជាពលរដ្ឋលើវិស័យទាំងប្រាំ ដូចជាសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និង បរិស្ថាន ផ្នែកសេវាកម្មរដ្ឋបាល និង សន្តិសុខ ផ្នែកយេនឌ័រ ដើម្បីឆ្លើយតប ទៅនឹង សេចក្តីត្រូវការជាអទិភាពទាំងនេះក្នុងការចូលរួមចំណែក លើកកំពស់ជីវភាពរស់នៅ និង សុខភាពរបស់ប្រជាពលរដ្ឋ អោយកាន់តែល្អប្រសើរឡើងជាងមុន បើនិយាយជារួមវិញផែនការប្រើប្រាស់ដីឃុំ ជាឧបករណ៏មួយដ៏សំខាន់ដែលជួយ ដល់ក្រុមប្រឹក្សាឃុំក៏ដូចជាខេត្តទាំងអស់នៅថ្នាក់ក្រោមជាតិក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង និង ប្រើប្រាស់ ធនធានធម្មជាតិប្រកបដោយចីរភាព និងប្រសិទ្ធភាព ។ ដូច្នេះការប្រើប្រាស់ដីឃុំ ជាការងារស្នូលសំរាប់អាជ្ញាធរគ្រប់ លំដាប់ថ្នាក់ពិសេសអាជ្ញាធរដែនដី និងមានមូលដ្ឋានអោយកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូល ផែនការ ប្រើប្រាស់ដីនៅក្នុងផែនការអភិវឌ្ឍន៏សេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក និងការ អនុម័តក្នុងការកសាងផែនការអភិវឌ្ឍន៏សេដ្ឋកិច្ចដោយមានការចូលរួមពី គ្រប់ភាគីពាក់ព័ន្ធក្នុងការចូលរួមសេដ្ឋកិច្ច ។

# ជំពូក ១

# ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសន្ទាត់

## ១.១ ស្ថានភាពទូទៅ

ឃុំសាមគ្គីកាលពីដើមឡើយ មានឈ្មោះថាឃុំណងប៉ាក ស្ថិតនៅក្នុងស្រុក បរកែវ ។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ កងទ័ពខ្មែរក្រហមនៅតែបន្តសង្គ្រាមចូលវាយឆ្មក់មកលើអ្នកភូមិដដែល ។ ឃុំនោះសំបូរទៅដោយព្រៃធំក្រាស់ៗ មានស្ថានភាពស្មុកស្មាញងាយស្រួលក្នុងការលាក់ខ្លួនរបស់ពួកខ្មែរក្រហម ។ នៅពេលទាហានខ្មែរក្រហមចូលមកម្តងៗ តែងតែធ្វើបាបដល់អ្នកភូមិ ហើយវាបានឃោសនាអូសទាញអោយអ្នកភូមិចូលទៅខាងក្រុមវាទៀតផង ។ ប៉ុន្តែដោយពុំអាចយកឈ្នះបានកងទ័ពខ្មែរក្រហមមួយចំនួន បានចេញមកសារភាពជាមួយរាជរដ្ឋាភិបាលហើយបានរស់នៅជួបជុំគ្រួសារ បងប្អូនញាតិសណ្តានក្នុងភូមិឃុំរបស់ខ្លួនវិញ ។ នៅពេលនេះហើយដែលចាស់ទុំភូមិមានគំនិតវៃឆ្លាតមានវិធីសាស្ត្រមួយគឺអប់រំអោយអ្នកភូមិដឹងពីគំនិតទាហានខ្មែរក្រហមដែលចូលសារភាពធ្លាប់រស់នៅក្នុងព្រៃចេះស្រលាញ់គ្នា ចេះសាមគ្គីគ្នាអោយបានល្អ ។ អញ្ចឹងហើយបានជានៅឆ្នាំ ១៩៨០ ឃុំណងប៉ាកបានប្តូរឈ្មោះមកជាឃុំសាមគ្គី ហើយដាក់បញ្ចូលមកក្នុងស្រុកអូរជុំវិញ ។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| **ខេត្ត** | **រតនគិរី** | |
| **ស្រុក** | **អូរជុំ** | |
| **ឃុំ** | **ឈ្មោះ សាមគ្គី** | **លេខកូដ:** ១៦០៦០៦ |
| **ចំនួនភូមិ** | **៤ ភូមិ ក្នុងនោះមាន** : ភូមិកាម៉ែន.ភូមិញ៉ុក.ភូមិពីង.ភូមិប្រាក់ | |

ឃុំសាមគ្គី ស្ថិតនៅប៉ែកខាងកើតនៃទីរួមខេត្តក្នុងស្រុកអូរជុំ ដែលមានទីតាំងនៅភូមិញ៉ុក មានចំងាយប្រមាណ ១៨ គីឡូម៉ែត្រ ពីទីរួមស្រុក និងស្ថិតនៅភាគខាងកើតនៃទីរួមខេត្តរតនគីរី មានចំងាយ ២៦គីឡូម៉ែត្រ ពីទីរួមខេត្តដែលមានព្រំប្រទល់ឃុំ ខាងកើតទល់ និងឃុំកិះចុងស្រុកបកែវខាងលិចទល់នឹងឃុំល្អក់ ខាងជើងទល់ និងឃុំប៉ូយ និងខាងត្បូងទល់នឹង ឃុំឯកភាព ។ សាលាស្រុកអូរជុំ បើគិតពីខេត្តមកឃុំសាមគ្គីមានចំងាយ ១៨ គីឡូម៉ែត្រ នាទិសបូពានៃទីរួមខេត្តរតនគីរី ។ ឃុំនេះមានផ្ទៃក្រឡាទំហំ **៥៩៨០ហិកតា** ចែកចេញជា ៤ ភូមិគឺ : ភូមិកាម៉ែន ភូមិញ៉ុក ភូមិពីង ភូមិប្រាក់ ។

ឃុំសាមគ្គីមានប្រជាជនសរុបចំនួន **២២៦៦ នាក់**ក្នុងនោះស្រី **១១៩១ នាក់** ដង់ស៊ីតេប្រជាជនមាន **៨៣នាក់**ក្នុងមួយគីឡូម៉ែត្រក្រឡា ។ របាយណ៍ប្រជាជនភាគច្រើនគឺប្រមូលផ្តុំនៅតាមបណ្តោយផ្លូវពីទីរួម ស្រុកទៅ ឃុំសាមគ្គី




រូបភាពទី ១ ផែនទីតាំងរដ្ឋបាល

## ១.១.២ ប្រជាសាស្ត្រ

ឃុំសាមគ្គីមានប្រជាជនសរុបចំនួន **២២៦៦ នាក់**ក្នុងនោះស្រី **១១៩១ នាក់** ដង់ស៊ីតេប្រជាជនមាន **៨៣នាក់**ក្នុងមួយគីឡូម៉ែត្រក្រឡា ។ របាយណ៍ប្រជាជនភាគច្រើនគឺប្រមូលផ្តុំនៅតាមបណ្តោយផ្លូវពីទីរួម ស្រុកទៅ ឃុំសាមគ្គី ចំណែកផ្នែកខាងជើងគឺពុំសូវមានប្រជាជនកុះករទេ តែក៏មានតាំងទីលំនៅជាការប្រមូល ផ្តុំរស់នៅតាមរដូវកាលសំរាប់

ការធ្វើកសិកម្ម (តាមខ្នមចាំចំការ) បន្តិចបន្តួចតែប៉ុណ្ណោះ ។ ប្រជាជននៅក្នុង ឃុំសាមគ្គីភាគច្រើនជាជនជាតិទំពួន ត្រឹងដែលសុទ្ធសឹងជាអ្នករស់នៅទីនោះតាំងតែពីឆ្នាំ ១៩៧៩មក ដោយឡែកជនជាតិភាគតិច ( ខ្មែរ ខ្មែរឥស្លាម ឡាវ ) ដែលមានវត្តមាននៅក្នុងតំបន់នេះគឺមានតិចតួចគឺ មានប្រមាណជា ២% តែប៉ុណ្ណោះ ។ តែក្នុងមួយ រយៈពេលចុងក្រោយនេះយើងសង្កេតឃើញមានការហូរចូលប្រជាជនមកពីខេត្តក្រៅ មកតាំងទីលំនៅក្នុងតំបន់នេះដែលមានចំនួនគួរឱ្យកត់សំគាល់គឺប្រមាណជា ២០% ដែលភាគច្រើនមកពីខេត្ត កំពង់ចាម តាកែវ និង ព្រៃវែង ។ លើកំណើនដដែលនេះក៏មានការកត់សំគាល់ទៅលើការថយចុះនៃអត្រាមរណៈរបស់កុមារផងដែរ ។ ចំពោះជំនឿសាសនា ប្រជាជននៅក្នុងឃុំ គឺមានលក្ខណៈដូចគ្នាទៅនឹងប្រជាជនក្នុងទីរួមខេត្តដែរគឺកាន់ព្រះពុទ្ធសាសនា ហើយនៅក្នុងឃុំក៏មានវត្តអារាមដែរតែទោះជាយ៉ាងនេះក្តីការសែនព្រេន និង ជំនឿលើអារ័ក្ស អ្នកតា ក៏នៅតែមានទៅតាមទម្លាប់របស់គេ ។

**តារាងស្ថិតិប្រជាជនឃុំសាមគ្គី ឆ្នាំ២០០៨ តាមក្រុមអាយុ**

| **ស្ថិតិតាមក្រុមអាយុ** | **ប្រុស** | **ស្រី** | **សរុប** | **ផ្សេងៗ** |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ១៣៩ | ១៥០ | ២៨៩ | |
| អាយុ ០៥ឆ្នាំ | ៧៤ | ៨៧ | ១៦១ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ១៤៣ | ១៨៨ | ៣៣១ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ១១៣ | ៩០ | ២០៣ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ៨០ | ៧៨ | ១៥៨ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ១០៤ | ១៥៨ | ២៦២ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ៣៨៨ | ៤១៨ | ៨០៦ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ៣៤ | ២២ | ៥៦ | អាយុចូលនិវត្តន៍ |
| **ប្រជាជនសរុប** | **១០៧៥** | **១១៩១** | **២៣២០** | |
| **ចំនួនគ្រួសារសរុប** | **៥១៧** | | | |

## ១.១.៣ ភាពគ្មានដីធ្លី

គ្រួសារដែលគ្មានដីផ្ទាល់ខ្លួនចំនួន ២៨ គ្រួសារ គ្រួសារប្រភេទនេះបច្ចុប្បន្នប្រកបមុខរបរធ្វើកសិកម្ម ដោយរបៀបប្រវាស និង មួយចំនួនរស់ដោយពឹងផ្អែកទៅលើការស៊ីឈ្នួល ពីសំណាក់អ្នកចំណាកស្រុក ដែលមានចំការកៅស៊ូធំៗ ក្រៅពីនេះគ្រួសារមួយចំនួនបានសុំដីក្នុងកូនកៅស៊ូដែលពុំទាន់ឡើងខ្ពស់ ដើម្បីធ្វើការដាំដុះ ជាដំណាំរដូវ ដូចជាសណ្តែកដី សណ្តែកសៀង និងដំណាំស្រូវជាដើម ។

គ្រួសារមានតិចជាង ១ហិកតា ប្រហែលជាមានចំនួន ៥ភាគរយ តែប៉ុណ្ណោះគ្រួសារទាំងនេះត្រូវរកចំនូលបន្ថែមដើម្បីផ្គត់ផ្គង់ជីវភាពអោយបានគ្រប់គ្រាន់ពួកគាត់ត្រូវ រកផល-អនុផលព្រៃឈើយកមកលក់នៅលើទីផ្សារ និង គ្រួសារ

មួយចំនួនទៀតត្រូវពឹងផ្អែកទៅលើការដើរស៊ីឈ្នួល ជំរះដី និង ដាំដំណាំផ្សេងៗ អោយអ្នកចំណាកស្រុកដែលមានចំការទ្រង់ទ្រាយធំ និងជាពិសេសពួកគាត់ពឹងផ្អែកទៅលើការចិញ្ចឹមសត្វ ដូចជា មាន់ ទា ជ្រូក ក្ងាន គោ ក្របី ជាដើម ។ ចំពោះចំនួនគ្រួសារដែលមានផ្ទះតាំងនៅលើដីចំណីផ្លូវដែលជាដីសាធារណៈនៅក្នុងឃុំទាំងមូល គឺពុំមានឡើយព្រោះនៅតំបន់នេះប្រជាពលរដ្ឋ ដែលជាជនជាតិទំពួន មានទំលាប់តាំងលំនៅដ្ឋានដាច់ឆ្ងាយពីផ្លូវ ហើយរស់នៅប្រមូលផ្តុំគ្នា ។ មិនតែប៉ុណ្ណោះប្រជាពលរដ្ឋនៅតំបន់ខ្ពង់រាបនេះមានទំលាប់ទៅរស់នៅតាមចំការដើម្បីដាំដុះក្នុងរដូវធ្វើចំការលុះប្រមូលផលរួចរាល់ទើបត្រឡប់ចូលភូមិវិញ ។

### ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

ប្រជាជនឃុំសាមគ្គីមាន ៩០% ប្រកបរបរ ដូចជាធ្វើស្រែ,ចំការ ក្រៅពីការងារស្រែ ចំការ ពួកគាត់តែងតែឆ្លៀតឱកាស ត្បាញកំផាតាមលក្ខណៈប្រពៃណី ,ចិញ្ចឹមសត្វ ធ្វើសួនបន្លែតាមគ្រួសារ ដោយ ដាំដំណាំ ហូបផ្លែ និងបន្លែបង្កាផ្សេងៗទៀត ហើយផលិតផលដែលគាត់ផលិតបានពួកគាត់ទុកសំរាប់ធ្វើជាអាហារនិងមួយចំនួនទៀតយកទៅលក់ ឬដោះដូរជារបស់របរផ្សេងៗមុខរបរកសិកម្មនេះជារបរដែលគាត់មានការពឹងផ្អែកទាំងស្រុងក្នុងចំណោមកសិករទាំងអស់មានតែ៥៥%តែប៉ុណ្ណោះដែលមានស្រូវគ្រប់គ្រាន់សំរាប់ទទួលទានរយៈពេលពេញមួយឆ្នាំ។ប្រជាជនភាគច្រើនធ្វើស្រែវស្សា៣៥%នៃចំនួនគ្រួសារកសិករ នៅធ្វើកសិកម្មពនេចរនៅឡើយទិន្នផលស្រូវជាមធ្យមទាប គឺទទួលបានប្រមាណជា១,៥០តោនក្នុងមួយហិកតា។ ក្រៅពីកសិកម្មប្រជាជនមានការពឹងពាក់ទៅលើព្រៃឈើ ដូចជាការ បោចវល្លិ៍ ផ្តៅ ជ័រទឹក ជ័រចុង ផ្សិត និងបន្លែបង្ការព្រៃ រុករកចាប់សត្វដូចជា អណ្តើក ត្រកួត។ល។ លើសពីនេះក៏នៅមានឈើសំណង់ ដែលផ្គត់ផ្គង់សំរាប់ការសាងសង់សំណង់ផ្សេងៗក្នុងទីរួមខេត្តទៀតផង។

### ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

ឃុំសាមគ្គីមានកំរិតសិក្សាដល់បឋម មានសាលារៀនចំនួន ១ ដែលមាន ៣ បន្ទប់ ស្មើនឹង ៣ ថ្នាក់ មានគ្រូបង្រៀនចំនួន ២ នាក់ ដែលមានសិស្សបឋម ៣៣១ នាក់ ក្នុងនោះសិស្សស្រី ៩០ នាក់ ចំពោះសិស្សដែលមិនបានចូលរៀនមានចំនួន ២៨៨នាក់ សិស្សស្រី១៥០នាក់ ស្មើ៧៩.៧៩% សិស្សប្រុស១៣៨ នាក់ ស្មើ៩៦.៥០% ។ បើតាមការពិនិត្យជាក់ស្តែង ក្នុងឃុំនេះមានការខ្វះខាតថ្នាក់រៀន អនុវិទ្យាល័យ និងវិទ្យាល័យ រីឯអត្រាសិស្ស មិនបានចូលរៀននេះគឺមកពី :

- បញ្ហា ខ្វះគ្រូបង្រៀន បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ

- ដោយឡែកចំពោះសិស្សដែលបានបញ្ចប់ការសិក្សាបឋមសិក្សា នៅឃុំសាមគ្គីនោះត្រូវជួបបញ្ហាដោយសិស្សត្រូវបន្តទៅរៀននៅអនុវិទ្យាល័យ និង វិទ្យាល័យ នៅទីរួមខេត្តដែលមានចំងាយផ្លូវជាង២៦គ.ម ដូច្នេះចំពោះសិស្សដែលក្រីក្រត្រូវបោះបង់ចោលការសិក្សា ។ សាលារៀននៅឃុំសាមគ្គីបច្ចុប្បន្ន ភាគច្រើនជាអាគារធ្វើពីថ្ម ចាក់បេតុងដែលមានការឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាល និង រដ្ឋាភិបាល ។

តារាង ស្ថិតិសាលា និងចំនួនសិស្ស ប្រចាំឆ្នាំ ២០០៨

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សសរុប | សិស្សស្រី | |
| ថ្នាក់មត្តេយសិក្សា | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ថ្នាក់បឋមសិក្សា | ១ | ៣ | ៣ | ៣៣១ | ៣៣១ | ១៨៨ | ២៨៨ |
| ថ្នាក់អនុវិទ្យាល័យ | 0 | 0 | 0 | 0 | 0 | 0 | 0 |

ប្រភព: របាយការណ៍ ស្ដីពីស្ថានភាពឃុំសាមគ្គី ឆ្នាំ ២០០៨




រូបភាពទី ២ សាលាបឋមសិក្សាសាមគ្គី

# ១.១.៦ ស្ថានភាពសុខាភិបាល

## ១.១.៦ ស្ថានភាពសុខាភិបាល

### ១.១.៦.១ ផ្នែកសុខាភិបាល

ឃុំសាមគ្គីមានប៉ុស្តិ៍សុខភាព១ខ្នង ដែលជាអំណោយសម្ដេចឪសម្ដេចម៉ែ ទោះបីមានប៉ុស្តិ៍សុខភាពក៏ដោយពេលមានជំងឺម្ដងៗពិបាករកមធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូនអ្នកជំងឺទៅកាន់មណ្ឌលសុខភាពផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយឃុំនៅតែខិតខំប្រឹងប្រែងសំរេចអោយបាននូវអណ្ដូងទឹកស្អាត (អណ្ដូងលូ អណ្ដូងស្នប់) ស្ថិតនៅក្បែរសាលា

ស្រុកអូរជុំបើគិតពីចំងាយផ្លូវពីភូមិមកមណ្ឌលសុខភាពមានចំងាយ១២គីឡូម៉ែត្រ។ ចំពោះសេវាសុខភាពនៅក្នុងឃុំនេះពុំទាន់បានបំពេញនូវសេចក្តីត្រូវការរបស់ប្រជាជនទូទាំងឃុំនៅឡើយ ព្រោះមិនមានគ្រូពេទ្យប្រចាំការសំរាប់ថែទាំសុខភាពគ្រប់គ្រាន់នៅឡើយ។ ម៉្យាងទៀតគ្រូពេទ្យដែលបំរើការងារសព្វថ្ងៃមានជំនាញមានកំរិតរីឯសេវាផ្សព្វផ្សាយពីការថែទាំសុខភាពមិនទាន់បានទូលំទូលាយ កត្តានេះហើយបានធ្វើអោយប្រជាជនមួយចំនួន គាត់មិនបានទៅសេវាសុខភាពទេ ។ អ្នកភូមិមួយចំនួននៅពេលគាត់មានជំងឺធ្ងន់ធ្ងរពួកគាត់តែងតែមានការកាប់គោជ្រូកឬមាន់ដើម្បីសែនព្រេន អ្នកភូមិខ្លះទៀតក៏មកព្យាបាលនៅពេទ្យខេត្តដែលមានចំងាយផ្លូវ២៦គីឡូម៉ែត្រទោះបីពិបាកក្នុងការធ្វើដំណើរយ៉ាងណាក៏ដោយ។ ផ្អែកទៅតាមស្ថានភាពភូមិសាស្រ្តនៃឃុំសាមគ្គី ដែលមានប្រជាជនរស់នៅតាមភូមិដាច់ឆ្ងាយពីគ្នានិងមានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពបណ្តាលអោយមានការលំបាកក្នុងការធ្វើដំណើរ ដូច្នេះការផ្តល់សេវាកម្មផ្នែកសុខភាពមិនទាន់គ្រប់គ្រាន់ ។

<u>តារាងស្ថិតិមណ្ឌល/ប៉ុស្តិ៍សុខភាព និងចំនួនគ្រូពេទ្យ</u>

| ល.រ | មណ្ឌល/ប៉ុស្តិ៍សុខភាព | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មណ្ឌលសុខភាព | ០ | ០ | ០ | ០ | ០ |
| ២ | ប៉ុស្តិ៍សុខភាពឃុំ | ១ | ៤ | ១ | ២ | ០ |



រូបភាពទី ៣ ប៉ុស្តិ៍សុខភាពសាមគ្គី

### ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ចំពោះសេវានៃការប្រើប្រាស់ទឹកស្អាតប្រជាជននៅក្នុងឃុំសាមគ្គីមានអណ្តូងទឹក ចំនួន ៧ អណ្តូង និង អណ្តូងស្នប់ចំនួន២ ដែលឧបត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាល ហើយបើគិតទៅលើគ្រួសារដែលបានប្រើទឹកអណ្តូង មានចំនួនតែ ៤គ្រួសារស្មើ ០.៧៧ភាគរយ អណ្តូងលូ២៨០ គ្រួសារស្មើ៥៤.១៦ភាគរយ ប្រើទឹកបឹង ត្រពាំង អាងទឹក ២២៩គ្រួសារ ស្មើ៤៤.២៩ភាគរយ ។ រីឯការប្រើប្រាស់បង្គន់អនាម័យប្រជាជនឃុំសាមគ្គី មិនមានបង្គន់អនាម័យ ចំនួន ៥១៧គ្រួសារ ស្មើ៩០ភាគរយ ដូចនេះធ្វើអោយ ប្រជាជនខ្លះគាត់តែងតែមាន ជំងឺរាករូសជាញឹកញាប់ ។
តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំសាមគ្គី

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត | |
| ១ | អណ្តូងស្នប់ | ៣ | ២ | ១ | ខូចត្រូវជួសជុលឡើងវិញ |
| ២ | អណ្តូងលូ | ៣១ | ១២ | ១៩ | ខូចត្រូវស្តារឡើងវិញ១កន្លែង |

## ១.២ ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

ភូមិសាស្ត្រឃុំសាមគ្គីមានរាងទ្រវែង បណ្តោយប្រមាណជា ២០ គម. និងទទឹងប្រមាណជា ៥គម. បញ្ចិតលាតសន្ធឹងយ៉ាងវែងតាមទិសដៅពីកើត មកទិសលិច ផ្នែកខាងជើងនៃឃុំស្ថិតនៅជាប់នឹងឃុំប៉ូយ និង ខាងត្បូងទល់ នឹងឃុំឯកភាព ផ្ទៃដីឃុំទាំងមូល តំបន់នេះជាតំបន់ខ្ពង់រាប ។

ឃុំមានលក្ខណៈភូមិសាស្ត្រប្រជាជនទូទៅប្រកបមុខរបរធ្វើចំការដោយស្ថានភាពអំណោយផល ឃុំសាមគ្គី ដូចជា តំបន់ខ្ពង់រាបដែលពុំមាន ទន្លេ ស្ទឹង ឬព្រៃក អ្វីឡើយ ។ ប៉ុន្តែឃុំនេះសំបូរទៅដោយអូរធម្មជាតិតូចៗ ជាច្រើនផងដែរដែលជាលក្ខណៈអំណោយផលរបស់ធម្មជាតិ ។ អ្នកភូមិអាចរក ត្រី ក្តាម ខ្យង កង្កែប អណ្តើក កំពឹស បានខ្លះៗ តាម ដងអូរទាំង ។ ដោយស្ថានភាពអំណោយផល ឃុំសាមគ្គីភាគច្រើនប្រជាជនប្រកបមុខរបរធ្វើចំការ និងដាំកូនឈើដំណាំហូបផ្លែ ដំណាំផ្សេងៗ និងការចញ្ចឹមសត្វ រកផល-អនុផលព្រៃឈើជាដើម ។




រូបភាពទី ៤ ផែនទីរយៈកំពស់ សាមគ្គី

### ១.២.២ អាកាសធាតុ

កំពស់ទឹកភ្លៀង ៩៣៥.៤ មីលីម៉ែត្រ ទិន្នន័យនេះជាទិន្នន័យស្រុកអូរជុំ ខេត្តរតនគិរី ដោយឡែកបច្ចុប្បន្ន មិនទាន់មានទិន្នន័យសំរាប់ឃុំនៅឡើយទេ ។ រយៈពេលនៃរដូវប្រាំងមានចំនួន ៥ខែ គឺចាប់ពីខែ មករា ដល់ខែ ឧសភា និង រយៈពេលរដូវវស្សាចាប់ពីខែ មិថុនា ដល់ខែ ធ្នូ ហើយចំពោះការប្រែប្រួលមានលំអៀងតិចតួចដោយជួនកាលអាចរាំង តាំងពីពាក់កណ្តាលខែធ្នូ ។

### ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

ឃុំសាមគ្គី ស្រុកអូរជុំ ខេត្តរតនគិរី ស្ថិតនៅប៉ែកខាងកើតនៃទីរួមស្រុកអូរជុំដែលមានទីតាំងនៅភូមិញ៉ាកមានចំងាយប្រមាណ១៨ គីឡូម៉ែត្រពីទីរួមស្រុក និងស្ថិតនៅភាគខាងជើងឈាងខាងកើតនៃទីរួមខេត្តរតនគិរី ។

ឃុំសាមគ្គីមានផ្លូវក្រាលគ្រួសក្រហមភ្ជាប់មកពីទីរួមខេត្តរតនគិរីកាត់តាមសាលាស្រុកអូរជុំ មកដល់សាលាឃុំ ដែលមានចម្ងាយប្រមាណ២៦គម ចំពោះនៅរដូវវស្សាវិញគឺពិបាកក្នុងការធ្វើដំណើរណាស់តែយើងអាចធ្វើដំណើរតាមផ្លូវជាតិលេខ ៧៨ ដោយកាត់តាមសាលាឃុំឯកភាព មកដល់សាលាឃុំ ដែលមានចម្ងាយប្រមាណ ២៥ គីឡូម៉ែត្រពីទីរួមខេត្ត។ នេះជាហេដ្ឋារចនាសម្ព័ន្ធផ្លូវគោកយ៉ាងសំខាន់សំរាប់ដឹកជញ្ជូន ទិន្នផលកសិកម្ម របស់ប្រជាពលរដ្ឋក្នុងឃុំមកកាន់ទីរួមខេត្ត។



រូបភាពទី ៥ ផ្លូវលំនៅក្នុង សាមគ្គី

## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ក្នុងឃុំសាមគ្គីមានចំណាត់ថ្នាក់នៃការប្រើប្រាស់ដីលំអិតចំនួន ១៥ ប្រភេទរួមមានដីលំនៅដ្ឋានភូមិ (ផ្ទះ-ឈើហូបផ្លែ) កន្លែងកប់ខ្មោច(ដីកន្លែងកប់ខ្មោច) ស្រូវវស្សា ដីកសិកម្មពនេចរ(ដីចំការផ្លាស់វេន )ចំការកៅស៊ូព្រៃស្រោងស្ងួត (ព្រៃញាតមានឈើធំៗ) ព្រៃល្បោះ ព្រៃល្បោះស្ងួត ព្រៃចំរុះ(ស្រោង និងរបោះ) ព្រៃដុះឡើងវិញ (ព្រៃកម្ពោធ ) វាលស្មៅ (ស្រែបោះបង់) ចំការបោះបង់ដុះស្មៅ (ព្រៃឫស) ព្រៃគម្ពោធ ចំការបោះបង់ដុះព្រៃគម្ពោធ ព្រៃគម្ពោធលាយដើមឈើធំមួយៗ បឹង អូរ-ស្ទឹង-ទន្លេ វាលភក់និងប្រភេទនៃការប្រើប្រាស់ដីសាមញ្ញ ៦

ប្រភេទរួមមាន ដីលំនៅដ្ឋានភូមិ (ផ្ទះ-ឈើហូបផ្លែ) កន្លែងកប់ខ្មោច(ដីកន្លែងកប់ខ្មោច) ដីកសិកម្ម ( ដីចំការ ) ព្រៃឈើ វាលស្មៅ វាលស្បូវ ប្រភពទឹក ដីដែលគ្មានរុក្ខជាតិដុះគ្រប ដណ្តប់ ។

**តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត**

| លរ | ប្រភេទនៃការប្រើប្រាស់ដី | ទំហំ (ហត) | | ចំណាត់ថ្នាក់របស់មូលដ្ឋាន |
|---|---|---|---|---|
| | | ម$^{២}$ | ហត | |
| ១ | ដីលំនៅដ្ឋានភូមិ | ១១៤៧៤៩ | ១២ | ផ្ទះ-ឈើហូបផ្លែ |
| ២ | កន្លែងកប់ខ្មោច | ៥៤៣២៨ | ៥ | ដីសំរាប់កប់ខ្មោច |
| ៣ | ស្រូវវស្សា | ៣០៩៨៥៨ | ៣១ | ស្រូវវស្សា |
| ៤ | ដីកសិកម្មពនេចរ | ១១៣៨២១១៩ | ១១៣៨ | ដីចំការផ្លាស់វេន |
| ៥ | ព្រៃស្រោងស្ងួត | ២៣០៥៧៤៣៨ | ២៣០៦ | ព្រៃញាតមានឈើធំៗ |
| ៦ | ព្រៃចំរុះ(ស្រោង និងរបោះ) | ១០៥៥២២៩៩ | ១០៥៥ | ព្រៃចំរុះ (ស្រោង និងរបោះ) |
| ៧ | ព្រៃដុះឡើងវិញ | ៩៩៥០៤៥៣ | ៩៩៥ | ព្រៃកម្លោច |
| ៨ | វាលស្មៅ | ២០៧៧១៩៤ | ២០៧ | ស្រែបោះបង់ |
| ៩ | ចំការបោះបង់ដុះស្មៅ | ៤៣៨ | ០.៤៣៨ | ព្រៃបួស |
| ១០ | ចំការបោះបង់ដុះព្រៃកម្លោច | ៩១៣១១១០ | ៩១៣ | ចំការបោះបង់ដុះព្រៃកម្លោច |
| ១១ | ព្រៃកម្លោចលាយដើមឈើធំមួយៗ | ២០៩២២៤៩ | ២០៩ | ព្រៃកម្លោចលាយដើមឈើធំមួយៗ |
| ១២ | វាលភក់ | ២១៤៧២៧ | ២២ | វាលភក់ |
| **សរុប** | | **៥៩៨០០៥៨៥២** | **៥៩៨០** | |

**ប្រភព : (លំអិតអំពីប្រភេទនៃការប្រើប្រាស់ដីនីមួយៗ មានពិពិណនាលំអិតនៅក្នុងឧបសម្ព័ន្ធ ១ និងមានភ្ជាប់ជាមួយនូវផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញ ខ្នាត A៣)**

### ១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី

ក្នុងឃុំទាំងមូលបើនិយាយអំពីកម្មសិទ្ធិដីរបស់ប្រជាពលរដ្ឋគឺបានការចុះបញ្ជី និងការចេញប័ណ្ណសំគាល់អចលនវត្ថុជូនដល់ប្រជាពលរដ្ឋខ្លះហើយ តែចំពោះដីកសិកម្មពនេចរ គឺពួកគាត់មានការគ្រប់គ្រង និងកាន់កាប់តាមបែបប្រពៃណី ។ បច្ចុប្បន្នដោយសារមានអ្នកចំណូលថ្មីច្រើនចូលទៅតាំងទីលំនៅក្នុងឃុំនោះការទិញលក់ដីបានកើតមានឡើង។ ការកាប់រានយកដីបានកើតមានជា រូបភាពតូចតាចដែលភាគច្រើនគឺកើតមានឡើងតាមបណ្តោយផ្លូវគ្រួសក្រហមដែល

មានលក្ខណៈងាយស្រួលក្នុងការធ្វើចរាចរ។ និយាយរួមក្រៅពីដីលំនៅដ្ឋានស្ទើរតែទាំងអស់នៃផ្ទៃដីគឺជាដីសាធារណៈរបស់រដ្ឋ។

<u>តារាងសង្ខេបស្ថានភាពកាន់កាប់ និង គ្រប់គ្រងដី</u>

| លរ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហត) | ផ្សេងៗ |
|---|---|---|---|
| ១ | ដីលំនៅដ្ឋាន | ១២ | ១កន្លែងស្ថិតនៅតាមដងផ្លូវក្រាលគ្រួសក្រហម |
| ២ | ដីស្រែ | ៣១ | ដីស្រែមាន ៣ កន្លែង ដែលស្ថិតនៅក្នុងឃុំទាំងស្រុង |
| ៣ | ដីចំការកសិកម្មពនេចរ | ១១៣៨ | ចំការ ដែលស្ថិតនៅក្នុងឃុំទាំងស្រុង |

### ១.៣.៣ ស្ថានភាពកសិកម្ម

ប្រជាជនឃុំសាមគ្គី ចំនួន ៩០ភាគរយ នៃចំនួនគ្រួសារដែលប្រកបរបរធ្វើ កសិកម្មពនេចរ តំបន់ដីនេះជាតំបន់ដែលពុំសូវមានជីជាតិ ទិន្នផលស្រូវទាបគឺប្រមាណជា ១.៥ តោន ក្នុងមួយហិកតា ដោយឡែកកសិកម្មពនេចរគឺធ្វើបានផលល្អប្រសើរតែក្នុងរយៈឆ្នាំទី១តែប៉ុណ្ណោះ ហើយដីនេះត្រូវបាន បោះបង់ចោល រហូតទៅដល់ខួបពី ៨ ដល់ ១០ឆ្នាំទើបអាចវិលមកធ្វើកសិកម្មសារជាថ្មីលើដីនោះវិញបាន។



**រូបភាពទី ៦** ការផ្លាស់ប្តូរកសិកម្មពនេចរ មកជាចំការយុទ្ធសាស្ត្រ

**តារាងក្រឡាផ្ទៃតាមផលិតភាពដី  ការប្រើប្រាស់ និង ផលិតផល**

| ល.រ | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមមូលដ្ឋាន) | ផ្ទៃក្រឡា ហិកតា |
|---|---|---|---|
| ១ | ដីមានផលិតភាពខ្ពស់ | ល្បាយឥដ្ឋ-កណ្តេងប្រផេះល្បាប់អាចម៏កណ្តុរ | |
| ២ | ដីលំនៅដ្ឋានភូមិ | ននោង,ត្រឡាច,ល្ពៅ,ស្លឹកគ្រៃ,ខ្ញី,ជី,ត្រប់,ចេក,ដូង... | ១២ |
| ៣ | កន្លែងកប់ខ្មោច | ដីសំរាប់ត្រៀមកប់ខ្មោចដែលបានបំរុងទុក | ៥ |
| ៤ | ស្រូវវស្សា | ដីសំរាប់ធ្វើស្រូវរយៈពេល៦ខែ ( មិថុនា-ធ្នូ ) | ៣១ |
| ៥ | ដីកសិកម្មពនេចរ | ស្រូវចំការ,សណ្តែកសៀង,ដំឡូងមី,អំពៅ........ | ១១៣៨ |
| ៦ | ព្រៃស្រោងស្ងួត | បេង,ធ្នង់,នាងនួន,គគីរ កកោះ ស្រឡៅ ឈើទាល.... | ២៣០៦ |
| ៧ | ព្រៃចំរុះ ( ស្រោង និង របោះ) | កូនឈើច្រើនប្រភេទដុះ | ១០៥៥ |
| ៨ | ព្រៃដុះឡើងវិញ | ខ្លុង ត្បែង....... | ៩៩៥ |
| ៩ | វាលស្មៅ | ដើមកន្ទ្រើងខែត ស្មៅគ្រែង ប្រឡាឆ្អឹងពស់....... | ២០៧ |
| ១០ | ចំការបោះបង់ដុះស្មៅ | ដើមឈូករត្ន័ព្រៃ ដើមស្រូល ដើមឃុស ដើមល្បៀង.... | 0 |
| ១១ | ចំការបោះបង់ដុះព្រៃគម្ពោធ | វាលស្មៅ និងដើមឈើមួយ | ៩១៣ |
| ១២ | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ឆ្លីក,ត្រយឹង,ស្តៅ,អង្គ្រង | ២០៩ |
| ១៣ | វាលភក់ | ដីវាលភក់ មិនអាចធ្វើកសិកម្មបាន | ២២ |
| **សរុបទាំងអស់** | | | **៥៩៨0** |

ប្រភព: ទិន្នន័យ GIS ថ្នាក់ជាតិ/សមាសភាគរៀបចំដែនដី/អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

## ១.៣.៤  ធនធានធម្មជាតិ

### ១.៣.៤.១  ធនធានព្រៃឈើ

ឃុំសាមគ្គីមាន ផ្ទៃដីសរុបចំនួន ៧ ១៥៦ ហិកតា ក្នុងនោះព្រៃស្រោងមានចំនួន ១ ៣៤១ ហិកតាព្រៃពាក់កណ្តាលស្រោងមាន ចំនួន ១៦៧៣ ហិកតាព្រៃល្បោះមានចំនួន ៨៤៤ ហិកតា ។ ទិន្នន័យនោះត្រូវបានគណនាដោយផ្អែកតាមផែនទីគំរបព្រៃឈើឆ្នាំ២០០២ ។ បើពិនិត្យមើលតាមផែនទីគំរបព្រៃឈើ ឆ្នាំ ២០០២ នោះឃើញថាឃុំសាមគ្គីមានធនធានព្រៃឈើច្រើនជាងគេក្នុងចំណោមឃុំទាំង ៧ នៃស្រុកអូរជុំ ។ សម្បត្តិព្រៃឈើទាំងត្រូវបានបាត់បង់បន្តិចម្តងៗ ដោយសារការបំផ្លិចបំផ្លាញពីជនខិលខូចមួយចំនួនតូចបានកាប់ឈើដើម្បីលក់យកប្រាក់ ការឈូសឆាយ កាប់រាន

ហ៊ុមព័ទ្ធយកដីព្រៃឈើធ្វើជាកម្មសិទ្ធិដោយខុសច្បាប់ ការលក់ដីធ្លីរបស់អ្នកភូមិ បងប្អូនជនជាតិដើមភាគតិចក្នុងសហ-គមន៍ និងការកាប់ព្រៃឈើដើម្បីធ្វើកសិកម្មពនេចរតាមលក្ខណៈប្រពៃណីរបស់ពួកគាត់ ។

ប៉ុន្តែបច្ចុប្បន្នប្រជាពលរដ្ឋនៅឃុំសាមគ្គី បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការថែរក្សាសម្បត្តិព្រៃឈើដ៏មានតំលៃទាំងនេះឡើងវិញ ដោយបានលើកគំរោងនៅថ្នាក់ឃុំរៀបចំបង្កើតសហគមន៍ព្រៃឈើឡើងវិញ ដោយមានការចូលរួមលើកទឹកចិត្ត និង ចូលរួមផ្តល់បច្ចេកទេសពីស្ថាប័នរដ្ឋបាលព្រៃឈើផងដែរ ។

#### ១.៣.៤.២ ធនធានជលផល

ឃុំសាមគ្គីជាតំបន់ខ្ពង់រាបដែលពុំមានទន្លេស្ទឹងឬព្រែកអ្វីឡើយ ។ប៉ុន្តែឃុំនេះសំបូរទៅដោយអូរធម្មជាតិតូចៗជាច្រើនផងដែរ ដែលជាលក្ខខណ្ឌអំណោយផលរបស់ធម្មជាតិ ។ អ្នកភូមិអាចរកត្រី ក្តាម ខ្យង កង្កែប អណ្តើក កំពីស បានខ្លះៗតាមដងអូរទាំងនេះដើម្បីបរិភោគជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ ទៅតាមប្រពៃណី ទំនៀមទំលាប់របស់បងប្អូនជនជាតិដើមភាគតិច ។ ចំនែកនៅរដូវប្រាំងអូរខ្លះរីង រីឯអូរខ្លះទៀតមិនរីងទេ អ្នកភូមិអាចរកម្ហូបទាំងនេះបានគ្រប់រដូវកាល ។ ប៉ុន្តែបច្ចុប្បន្នមច្ឆាជាតិទាំងនេះបានថយចុះជាបណ្តើរៗ ដោយសារជនខិលខូចមួយចំនួនបានប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ដូចជាឆក់ នឹងខ្សែភ្លើងជាដើម ។ ទោះបីជាយ៉ាងនេះក្តីប្រជាពលរដ្ឋបានខិតខំយកចិត្តទុកដាក់ការពារមច្ឆាជាតិទាំងនេះមិនអោយបាត់បង់ឡើយ ។

## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

ស្ថានភាពជាក់ស្តែង

- តម្លៃស្រូវ ១ គីឡូក្រាម = ១៤00 រៀល
- អង្ករ ១គីឡូក្រាម = ១៧00 រៀល
- សាច់ជ្រូក ១គីឡូក្រាម = ១៨.000 រៀល
- សាចត្រី ១គីឡូក្រាម = ១៥.000 រៀល
- មាន់ ១ តំលៃ = ២៥.000 រៀល
- សាច់គោ ១គីឡូក្រាម = ២0.000 រៀល
- គ្រឿងផ្ទះ ១ គូប = ៥00.000 រៀល
- ខ្សាច់ ១គូប = ៤0.000 រៀល
- គ្រួស ១ គូប = ៦0.000 រៀល
- សណ្តែកសៀង ១គីឡូក្រាម = ១៥00 ទៅ ១៨00 រៀល
- សណ្តែកដី ១គីឡូក្រាម = ២000 ទៅ ២៥00 រៀល

- ដំឡូងមី ១គីឡូក្រាម = ៥០០ រៀល
- ឪឡឹក ១តំលៃ =២៥០០ រៀល

### ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

- ការទិញចូលស្រូវអង្ករ បានទិញពីអ្នកភូមិ ជិតខាង និងភូមិខ្លួនឯង តែក៏មានមួយចំនួនតូចទិញពីផ្សារ ដែលអង្គនៅលើទីផ្សារត្រូវបាននាំចូលពីទីរួមខេត្ត ស្ថិតនៅក្រុងបានលុង ។
- ការលក់ចេញនូវ ផលអនុផលព្រៃឈើ ប្រជាជនបាននាំយកទៅលក់នៅទីរួមខេត្ត ជួនកាលក៏មានឈ្មួញមកពីក្រៅមកទិញដែរ ភាគច្រើនតម្រូវការរបស់ឈ្មួន រួមមានឈើ និងអនុផលព្រៃឈើខ្លះៗដែរ ។
- ចំពោះផលនេសាទវិញ សព្វថ្ងៃប្រជាជននៅក្នុងឃុំមិនមានការនាំចេញទេព្រោះការ រកផលនេសាទមានការថយចុះដូច្នេះប្រជាពលរដ្ឋរកបានត្រឹមតែបង្គ្រប់នៅក្នុងជីវភាពគ្រួសារតែប៉ណ្ណោះ ។

### ១.៤.៣ ឱកាស ឧបសគ្គ

នៅឃុំសាមគ្គី មានធនធានព្រៃឈើ ផ្តល់នូវប្រភពជាចំណីអាហារ អុស ឈើសំរាប់សំណង់ផ្សេងៗ និងអនុផលព្រៃឈើដទៃជាច្រើនទៀតរួមទាំងសត្វព្រៃផងដែរសំរាប់ប្រជាពលរដ្ឋក្នុងឃុំប្រើប្រាស់សព្វបែបយ៉ាង។ ប៉ុន្តែដោយសារធនធានព្រៃឈើទាំងនេះកំពុងតែរងការគំរាមគំហែងបាត់បង់ជាបណ្តើរៗ ហើយបានធ្វើអោយប្រជាពលរដ្ឋជួបប្រទះនូវបញ្ហានេះពីមួយថ្ងៃទៅមួយថ្ងៃ ។ កត្តានេះហើយដែលធ្វើអោយប្រជាពលរដ្ឋក្នុងឃុំនេះ ក៏ដូចជាឃុំទាំងមូលដែលបាត់នូវចំណូលសេដ្ឋកិច្ច ផងដែរ ។ ចំពោះការប្រកបមុខរបរធ្វើចំការ ដូចជា ការដាំដំណាំ ស្វាយចន្ទី ដំឡូងមី សណ្តែកដីសណ្តែកសៀង និង ដំណាំហូបផ្លែ ដទៃទៀត គឺជាធនធានមួយមានសក្តានុពល យ៉ាងខ្ពស់ និង ជាប្រភពចំណូលយ៉ាងសំខាន់សំរាប់ប្រជាពលរដ្ឋនៅក្នុងឃុំ ក៏ដូចជាសេដ្ឋកិច្ច ជាតិផងដែរ ។ តែបច្ចុប្បន្នការប្រើប្រាស់ធនធានមានការប៉ះពាល់ គឺធ្វើអោយធនធានទាំងនេះទទួលរងនូវការគ្រោះថ្នាក់យ៉ាងខ្លាំងដោយសារខ្វះទីផ្សារ និង មានតំលៃទាបជាដើម ។ ល ។

# ជំពូក២
# ការវិភាគតម្រូវការសំរាប់អនាគត

## ២.១ តំបន់រសើប

ភូមិកាម៉ែនធំ ឃុំសាមគ្គី ត្រូវបានចាត់ទុកជាតំបន់រសើប ។ ភូមិនេះសំបូរទៅដោយដីក្រហមដែលជាលក្ខណះអំណោយផលដីល្អ ដល់ដំណាំកៅស៊ូ ដំណាំស្វាយចន្ទី និងដំណាំផ្សេងៗទៀត ។ ហេតុនេះហើយបានជាប្រជាពលរដ្ឋដែលមកពីបណ្តាខេត្តមួយចំនួនដូចជា ខេត្តព្រៃវែង កំពង់ចាម និងខេត្តកំពង់ធំ ជាដើម បាននាំគ្នាសំរុកមកទិញដីក្រហមនៅភូមិនេះ ដើម្បីប្រកបមុខរបរធ្វើចំការតាមរដូវកាល ។ បងប្អូនសហគមន៍ភូមិកាម៉ែនបាននាំគ្នាលក់ដីធ្លីរបស់ពួកគាត់អស់ស្ទើរមួយភាគធំទៅអោយជនចំណាកស្រុកទាំងនោះ ។ ធនធានធម្មជាតិបានរងគ្រោះនូវការបំផ្លិចបំផ្លាញ និង បានបាត់បង់ជាបណ្តើរៗ ។ ដូចនេះ យើងមានវិធានការទប់ស្កាត់ការទិញ លក់ដីធ្លីដោយខុសច្បាប់ ដើម្បីថែរក្សាការពារធនធានធម្មជាតិនៃភូមិនេះអោយបានគង់វង្ស ។

ភូមិនេះមានតំបន់រសើបមួយកន្លែងមានផ្ទៃដីចំនួន ៣៦ ហិកតា ដែលសំបូរទៅដោយធនធានព្រៃឈើជាច្រើនមានដូចជាឈើទាល ផ្ចឹក ស្រឡៅ កកោះ បេងធ្នង់...រួមទាំងពពួកសត្វព្រៃទាំងពូងផលដែរ ។ ព្រៃឈើទាំងនេះមានសារៈសំខាន់ណាស់សំរាប់អ្នកភូមិកាម៉ែន ។ ហេតុនេះហើយតំបន់នេះត្រូវគេការពារ និង អភិរក្សធនធានធម្មជាតិទាំងនេះអោយបានគង់វង្សប្រកបដោយនិរន្តភាព ។ ក្នុងឆ្នាំ២០០៩ នេះក្រោមគំរោងមូលនិធិឃុំប្រជាពលរដ្ឋនៅក្នុងភូមិបានរួមសហការជាមួយស្ថាប័នជំនាញរដ្ឋបាលព្រៃឈើបាន នឹងកំពុងរៀបចំតំបន់ព្រៃឈើនេះបង្កើតទៅជា "ព្រៃសហគមន៍" ដើម្បីបានទទួលស្គាល់ដោយច្បាប់ ។

## ២.២ ការប្រឈម/ឧបស័គ្គ

ដោយតំបន់នេះ សំបូរទៅដោយធនធានធម្មជាតិ និង ដីជាប្រភេទដីក្រហម មានលក្ខណៈអំណោយផលដីល្អសំរាប់ដាំដំណាំកសិកម្មផ្សេងៗ នោះដូចនេះហើយ នឹង មានការប្រឈមក្នុងការកាប់រានឈ្មូសឆាយដីព្រៃយកមកធ្វើជាកម្មសិទ្ធិការលួចកាប់ឈើដោយខុសច្បាប់ របស់ជនខិលខូចមួយចំនួនជាដើម...។ ល ។ ទាំងនេះជាឧបស័គ្គរបស់អ្នកភូមិកាម៉ែនធំ ដែលនាំអោយបង្កដល់ការប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់ដែលពឹងផ្អែកក្នុងការរុករកផល-អនុផលព្រៃឈើ និង បេះបន្លែផ្លែឈើព្រៃយកមកធ្វើជាម្ហូបអាហារប្រចាំថ្ងៃរបស់អ្នកភូមិនៅក្នុងភូមិនេះ ។

ដោយសារជនចំណាកស្រុកបានមករស់នៅភូមិកាម៉ែននេះយ៉ាងច្រើនបានធ្វើអោយសក្តានុពលធនធានធម្មជាតិបានបាត់បង់ជាបណ្តើរៗ ។ អ្នកភូមិកាម៉ែនដែលមកពីមុនរស់នៅចិញ្ចឹមជីវិតដោយពឹងផ្អែកលើផលអនុផលព្រៃឈើ និងសត្វព្រៃឥឡូវបានជួបប្រទះការលំបាកខ្លះៗ។ ការស្វែងរក ម្ហូប ចំណីអាហារដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារតាមលក្ខណៈប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិចបានធ្លាក់ចុះមួយកំរិតគួរអោយព្រួយបារម្ភយ៉ាងខ្លាំង ។

## ២.៣ តម្រូវការ នៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំសាមគ្គី

**យុទ្ធសាស្ត្រអភិវឌ្ឍន៍ទី ១ :** កាត់បន្ថយភាពក្រីក្រ ពង្រីកប្រព័ន្ធគមនាគមន៍ និង កែលម្អជីវភាពរស់នៅតាមរយៈប្រព័ន្ធកសិកម្ម ។

- ប្រជាពលរដ្ឋក្មេង ចាស់ប្រុសស្រី មានជីវភាពរស់នៅប្រសើរឡើងតាមរយៈអនុវត្តបាននូវប្រព័ន្ធកសិកម្មចំនុះជាលក្ខណៈគ្រួសារ ដាំដំណាំយុទ្ធសាស្ត្រមានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ សំរាប់ស្រោចស្រប់ដីស្រែ ផ្លូវលំធ្វើដំណើរ ទៅមកដើម្បីងាយស្រួល បានដឹកជញ្ជូនផលិតផលកសិកម្មទៅវិញទៅមក និង អនុផលដែលកែច្នៃយកទៅលក់នៅទីផ្សា ពិសេសបានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថានបានប្រសើរឡើង ។

**យុទ្ធសាស្ត្រអភិវឌ្ឍន៍ទី ២ :** បង្កើនការប្រើប្រាស់ទឹកស្អាត ពង្រីកសេវាសុខាភិបាលមូលដ្ឋាន និងពង្រីកប្រព័ន្ធអប់រំកាត់បន្ថយភាពក្រីក្រ ។

- ប្រជាពលរដ្ឋ ទូទាំងឃុំមានសុខភាពរស់នៅប្រសើរឡើងតាមរយៈមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់មានសេវាសុខាភិបាលតាមមូលដ្ឋាន មានសេវាអប់រំដើម្បីបង្កើនធនធានមនុស្ស នឹងមានឱកាសបានចូលរួមចំណែកគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថានបានប្រសើរឡើង ។

**យុទ្ធសាស្ត្រអភិវឌ្ឍន៍ទី ៣ :** បង្កើនការគ្រប់គ្រង កាត់បន្ថយការបាត់បង់ធនធានធម្មជាតិ និង បរិស្ថាន ។

- ប្រជាពលរដ្ឋក្នុងឃុំនេះ មានជីវភាពរស់នៅល្អប្រសើរ តាមរយះយល់ដឹង ពីវិធីក្នុងការប្រើប្រាស់គ្រប់គ្រងថែរក្សា និងការពារធនធានធម្មជាតិ និង បរិស្ថានបានកាន់តែប្រសើរឡើង ។

**យុទ្ធសាស្ត្រអភិវឌ្ឍន៍ទី ៤ :** បង្កើនសុវត្ថិភាពសន្តិសុខមូលដ្ឋាន កាត់បន្ថយទំនាស់ផ្សេង ៗ

- ប្រជាពលរដ្ឋមានជីវភាពរស់នៅល្អប្រសើរ តាមរយៈពង្រីកប្រព័ន្ធកសាងផែនការនៅមូលដ្ឋាន យល់ដឹងពីច្បាប់ និងកាត់បន្ថយនូវបញ្ហាទំនាស់ផ្សេងៗព្រមទាំងចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថានបានកាន់តែប្រសើរឡើង ផងដែរ ។

**យុទ្ធសាស្ត្រអភិវឌ្ឍន៍ទី ៥ :** បង្កើនការយល់ដឹង ជំនាញវិជ្ជាជីវៈ ដល់ស្ត្រីយល់ដឹង ពីច្បាប់ក្នុងការទំនាក់ទំនងល្អ និងកាត់បន្ថយបញ្ហា កើតឡើងខុសច្បាប់ ។

-ប្រជាពលរដ្ឋនៅក្នុងឃុំនេះមានការរស់នៅល្អប្រសើរ មានបរុស ស្ត្រីមានសមភាព និងសមធម៌វាងគ្នាយល់ដឹងពីសិទ្ធិរស់នៅទប់ស្កាត់ការជួញដូរ និង ប្រឆាំងការរំលោភផ្លូវភេទស្ត្រី និង កុមារ កាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ ព្រមទាំងមានឱកាសបានចូលរួមយ៉ាងសកម្ម ក្នុងការគ្រប់គ្រង ធនធានធម្មជាតិ និង បរិស្ថាន ។

## ២.៤ តម្រូវការដីសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១ អត្រាកំណើន

ស្ថានភាពអត្រាកំណើននៃ ប្រជាពលរដ្ឋនៅក្នុង ឃុំសាមគ្គី បើពិនិត្យនៅក្នុងឆ្នាំ ២០០៥ មានការកើនឡើងតែ ៦ គ្រួសារ ចំពោះចំនួនមនុស្សឃើញថាមានចំនួនច្រើនជាងរហូតទៅដល់ ៨៧ នាក់ ស្មើ ០.៤៧ ភាគរយ តែឆ្នាំ បន្ទាប់

ទៅតាមបណ្តាឆ្នាំនីមួយៗឃើញថាមានការកើនឡើងគួរអោយកត់សំគាល់ ។

តារាង ការគណនាអត្រាកំណើនមធ្យម

| **ចំនួនគ្រួសារ/ប្រជាជន** | **២០០៥** | **២០០៦** | **២០០៧** | **២០០៨** | **កំណើនមធ្យម** | **កំណើន/ឆ្នាំ** |
|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | ៣៦៣ | ៤០៤ | ៣៤១ | ៥១៧ | - | - |
| អត្រាកំណើនគ្រួសារ | -៨.៦% | ១១.៣% | -១៥.៦% | ៥១.៦% | ១៦ % | ៨៣គ្រួសារ |
| ចំនួនប្រជាជនសរុប | ១៨០៧ | ២០២២ | ២០៩២ | ២២៨១ | - | - |
| អត្រាកំណើនប្រជាជន | ១០.៧% | ៥,៦៤% | ១,៣៨% | ៣,១០% | ៥ % | ១៣៩នាក់ |

## ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

តារាងការធ្វើចំណោលប្រជាសាស្ត្រ

| **ស្ថិតិតាមក្រុមអាយុ** | **ឆ្នាំ ២០១២** | | **ឆ្នាំ ២០១៧** | | **ឆ្នាំ ២០២២** | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** | |
| អាយុក្រោម០៥ឆ្នាំ | ៣៦០ | ១៨៧ | ៤៤៩ | ២៣៣ | ៥៣៧ | ២៧៩ | |
| អាយុ ០៥ឆ្នាំ | ២០១ | ១០៨ | ២៥០ | ១៣៥ | ២៩៩ | ១៦២ | |
| អាយុពី ៦-១១ឆ្នាំ | ៤១២ | ២៣៤ | ៥១៤ | ២៩២ | ៦១៥ | ៣៤៩ | |
| អាយុពី ១២-១៤ឆ្នាំ | ២៥៣ | ១១២ | ៣១៥ | ១៤០ | ៣៧៧ | ១៦៧ | |
| អាយុពី ១៥-១៧ឆ្នាំ | ១៩៧ | ៩៧ | ២៤៥ | ១២១ | ២៩៤ | ១៤៥ | |
| អាយុពី ១៨-២៤ឆ្នាំ | ៣២៦ | ១៩៧ | ៤០៧ | ២៤៥ | ៤៨៧ | ២៩៤ | |
| អាយុពី ២៥-៦០ឆ្នាំ | ១០០៤ | ៥២១ | ១២៥១ | ៦៤៩ | ១៤៩៨ | ៧៧៧ | |
| អាយុពី៦១ឆ្នាំឡើងទៅ | ៧០ | ២៧ | ៨៧ | ៣៤ | ១០៤ | ៤១ | |
| ចំនួនប្រជាជនសរុប | ២៨២២ | ១៤៨៣ | ៣៥១៧ | ១៨៤៩ | ៤២១២ | ២២១៤ | |
| **គ្រួសារ** | **៦៤៤** | | **៨០២** | | **៩៦១** | | |

អត្រាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំសាមគ្គី បើពិនិត្យទៅលើកំណើន ក្នុងរយៈពេល៥ ឆ្នាំម្តងសំរាប់រយៈពេល ១៥ឆ្នាំខាងមុខឃើញថាអត្រាកំណើនប្រជាពលរដ្ឋជាមធ្យម ១៦ ភាគរយក្នុងនោះស្មើ និង ៦៤២៦នាក់ ។

## ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋាននៅជនបទគឺ សំដៅទៅដល់ដី ដែលប្រើប្រាស់សំរាប់សង់ផ្ទះសម្បែង និង សំរាប់ដាំដំណាំសួនគ្រួសារនៅជុំវិញ (លំអិតសូមមើលឧបសម្ព័ន្ធ១)សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ១២ហិកតា សំរាប់ប្រជាជន

ប្រមាណជា ៥១៧គ្រួសារ ដូច្នេះទំហំដីសំរាប់មួយគ្រួសារគិតជាមធ្យមគឺមាន ០,២៥ ហិកតាដែលទំហំនេះអាចជាទំហំសមស្របសំរាប់ការតាំងលំនៅដ្ឋាន ។

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | | | |
|---|---|---|---|---|
| - ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋាន | ១ គ្រួ. | x ០,២៥ | = | ០.២៥ ហត. |
| - កំណើនគ្រួសារ ២០២០ | ៩៦១ គ្រួ. | x ០,២៥ | = | ២៤០,២៥ ហត. |
| | សរុប | | | **២៤០,៥០ ហត.** |

## ២.៤.៣ តម្រូវការដីកសិកម្ម

តម្រូវការដីកសិកម្មគឺរួមមានដីសំរាប់ចំការដំណាំ( លំអិតសូមមើលឧបសម្ព័ន្ធ១) សំរាប់ឆ្នាំ គោល ២០០៨ មានទំហំ២៣៣ហិកតាសំរាប់ប្រជាជនសរុប ៥១៧គ្រួសារ ដូច្នេះទំហំដីជាមធ្យម សំរាប់មួយគ្រួសារមាន១,៧៣ហិកតា។ តាមស្ថិតិគឺមានតែ៩០%តែប៉ុណ្ណោះដែលពឹងផ្អែកជាចំបងលើវិស័យកសិកម្មដែលអាចមានដីជាមធ្យមទំហំ២,៥០ហិកតា ដែលទំហំនេះអាចជាទំហំសមស្របសំរាប់ការធ្វើកសិកម្ម។

យោងតាមមាត្រា១៧ អនុក្រិត្យសម្បទានដីសង្គមកិច្ចឆ្នាំ២០០៣ ទំហំដីលំនៅដ្ឋានក្នុង០១ គ្រួសារ។ ដែលជាទំហំដីសមស្របសំរាប់ប្រជាជនមួយគ្រួសារ។

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | | | |
|---|---|---|---|---|
| - ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីកសិកម្ម | ១ គ្រួ. | x ២,៥ | = | ២.៥ហត. |
| - ចំនួនគ្រួសារមានដីតិចជាង ១ហិកតា | ០០ គ្រួ. | x ២ | = | ០ ហត. |
| - កំណើនគ្រួសារ ២០២២ | ៤៤៤ គ្រួ. | x ២,៥ | = | ២៤០២.៥ ហត. |
| | សរុប | | | **១១១២.៥ ហត.** |

យោងតាមឯកសារព័ត៌មាន ស្តីពីស្ថានភាពឃុំ សាមគ្គីក្នុងរយៈពេល០៣ឆ្នាំចុងក្រោយ គឺឆ្នាំ ២០០៦ ឆ្នាំ ២០០៧ និង ឆ្នាំ ២០០៨ ប្រជាពលរដ្ឋម្នាក់អាចទទួលបានបរិមាណស្រូវមធ្យមក្នុង ០១ឆ្នាំ ត្រឹមតែ ១៧០គក្រ ប៉ុណ្ណោះ គឺខ្វះប្រមាណ ៧០គក្រ នេះបើគិតតាមបទដ្ឋានគំរូរបស់អង្គការស្បៀងអាហារពិភពលោក ២៣៨-២៤០គក្រ /ឆ្នាំ។ តាមស្ថានភាពជាក់ស្តែង ឃុំអាចមានលទ្ធភាពពង្រីកដីស្រែវស្សាបានត្រឹមតែ ១១៤ហត ដែលអាចដោះស្រាយជូនត្រឹមតែប្រជាជនដែលគ្មានដីគ្មានដីតែប៉ុណ្ណោះ។ នៅឆ្នាំ ២០២២ បើទោះជាយើងអាចបង្កើនទិន្នផលស្រូវមធ្យមពី ០,៩តោន/ហត ដល់ទៅ១,២ តោន/ហត ក៏លទ្ធភាពផលិតស្បៀងរបស់ឃុំឯកភាព មិនអាចធានាសុវត្ថិភាពបានឡើយ ពោលគឺបានត្រឹមតែប្រមាណ ៨០ គក្រសំរាប់ម្នាក់ក្នុង០១ឆ្នាំ ប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ដើម្បីធានាជីវភាពរស់នៅ

របស់ប្រជាពលរដ្ឋនៅឆ្នាំ ២០២២ ឃុំឯកភាពនឹងផ្តោតលើសក្តានុពលភាពផ្សេងៗមួយចំនួន ទៀតរបស់ឃុំដូចជា: ដំណាំកៅស៊ូ ដំណាំសណ្តែកសៀង ដំណាំសណ្តែកដី ដំណាំដំឡូងមី ដំណាំដំឡូងជ្វា។

### ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ដោយនៅឃុំសាមគ្គី មានព្រៃឈើសំបូរបែប និង វាលស្មៅមួយចំនួននៅឡើយ ដូច្នេះដីដែលបានកំណត់នៅក្នុងតំបន់រសើប និង ដីផ្សេងៗទៀតដែលមិនបានកំណត់ទៅក្នុងប្រភេទប្រើប្រាស់ដីផ្សេងៗទៀត គឺត្រូវតែទុកឱ្យនៅជាដីព្រៃ និង វាលស្មៅសំរាប់កិច្ចការពារបរិស្ថាន និង ធនធានធម្មជាតិ ពិសេសគឺបណ្តា អូរធម្មជាតិដែលជាប្រភពដ៏ ចំបងសំរាប់ធនធានជលផល ដល់មនុស្សនៅក្នុងឃុំនេះ ។

### ២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម

ហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចៗគឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋានឬដីទីប្រជុំជនដោយមិនបានញែកចេញដោយឡែកនោះទេ (ក្នុងនោះដីកប់ខ្មោច និង វត្ត ក៏គិតគូរក្នុងនេះដែរ) តែក៏មានការគិតគូរជារួម លើកលែងតែហេដ្ឋារចនាសម្ព័ន្ធ សង្គមដែលមានទ្រង់ទ្រាយធំៗ ទើបមានការគិតគូរដោយឡែក ។ និយាយរួមដីសំរាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានកំណត់ជារួមជាមួយ នឹងដីត្រៀមបំរុង សំរាប់ពង្រីកទីប្រជុំជនផងដែរ។

តាមការប៉ាន់ប្រមាណជាសរុប ដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គមគឺមានតម្រូវការបន្ថែមចំនួន ចំពោះផ្លូវ តូចៗ គឺមិនមានការគិតជាផ្ទៃដីទេតែមានប្រវែងហើយនឹងបង្ហាញក្នុងផែនទីដោយឡែក។

**<u>តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ</u>**

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | 0 | ០១សាលា(៧បន្ទប់) | ០១សាលា(៧បន្ទប់) |
| សាលាបឋមសិក្សា | ០១សាលា(៣បន្ទប់) | ០៣សាលា(១៦បន្ទប់) | ០២សាលា(១៣បន្ទប់) |
| សាលាអនុវិទ្យាល័យ | ០០ | ០២សាលា(១០បន្ទប់) | ០២សាលា(១០បន្ទប់) |
| សាលាវិទ្យាល័យ | ០០ | ០១សាលា(៥បន្ទប់) | ០១សាលា(៥បន្ទប់) |
| ប៉ុស្តិ៍សុខភាព | ០១ | ០០ | ០០ |
| អណ្តូងទឹកស្អាត | ៣៣ | ០៣ | ០៣ |
| ប៉ុស្តិ៍នគរបាល | ០១ | ០០ | ០០ |
| សាងសង់លូកាត់ផ្លូវ | ០១ | ២កន្លែង | ២កន្លែង |

#### ២.៤.៥.១ តម្រូវការសាលារៀន

ទៅថ្ងៃខាងមុខ ឃុំសាមគ្គី ចាំបាច់ត្រូវសាងសង់សាលារៀនថ្មីបន្ថែមទៀត សំរាប់កំណើនប្រជាពលរដ្ឋជារៀង

រាល់ឆ្នាំ ។ គំរោងដែលការិយាល័យអប់រំស្រុកបានកំណត់ជ្រើសរើសនោះគឺស្ថិតនៅភូមិកាម៉ែនធំ ។ ការិយាល័យអប់រំស្រុកបានត្រៀមដីសំរាប់ការសាងសង់ចំនួន ១ ហិកតា រួមហើយដោយបានធ្វើសារពើភ័ណ្ឌជាទ្រព្យសម្បត្តិរបស់រដ្ឋយ៉ាងត្រឹមត្រូវ នឹងបានដាក់ស្នើ សុំសាងសង់ ទៅក្រសួងអប់រំ យុវជន និងកីឡារួចហើយដែរប៉ុន្តែនៅមិនទាន់បានការឆ្លើយតបនៅឡើយទេ ។

តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយសិក្សា | ២០១ | ០ | ២ | ២៥០ | ០ | ០ | ៥៣៧ | ១ | ៥ |
| ថ្នាក់បឋមសិក្សា | ៤១២ | ០ | ១ | ៥១៤ | ១ | ៦ | ២៩៩ | ២ | ៩ |
| ថ្នាក់អនុវិទ្យាល័យ | ២៥៣ | ១ | ៣ | ៣១៥ | ០ | ១ | ៦១៥ | ១ | ៦ |
| ថ្នាក់វិទ្យាល័យ | ១៩៧ | ០ | ២ | ២៤៥ | ០ | ០ | ៣៧៧ | ១ | ៣ |

## ២.៣.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

### ក.សេវាកម្មសុខភាព

ឃុំសាមគ្គីមានប៉ុស្តិ៍សុខភាព១ខ្នង ដែលជាអំណោយសម្តេចឱសម្តេចម៉ែ ទោះបីមានប៉ុស្តិ៍សុខភាពក៏ដោយពេលមានជំងឺម្តងៗពិបាករកមធ្យោបាយធ្វើដំណើរ និង ដឹកជញ្ជូនអ្នកជំងឺទៅកាន់មណ្ឌលសុខភាពផងដែរ ។

- ចំងាយមធ្យម ពីភូមិទៅមណ្ឌលសុខភាពឃុំចំពោះភូមិផ្នែកខាងលើ ១៣.៧៥គីឡូម៉ែត្រ ផ្អែកទៅតាមស្ថានភាព ភូមិសាស្ត្រ នៃឃុំសាមគ្គីដែលមានប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នានិងមានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពឃុំបណ្តាលអោយមានការលំបាកក្នុងការធ្វើដំណើរដូច្នេះការផ្តល់សេវាកម្ម ផ្នែកសុខភាពមិនទាន់គ្រប់គ្រាន់នៅឡើយ។

- ចំពោះការការពារសុខមាលភាពប្រជាពលរដ្ឋនៅក្នុងឃុំសាមគ្គី នៅចោទជាបញ្ហា ហើយនៅរយះពេល ១៥ឆ្នាំ ខាងមុខក៏នៅតែជួបបញ្ហាដដែលព្រោះថាស្ថានភាពប្រជាជនក្នុងឃុំរស់នៅតំបន់ខ្ពង់រាបមានចំនួន ៤ភូមិ ដែលគ្មានលទ្ធ ភាពចូលមកព្យាបាលនៅមណ្ឌលសុខភាពឃុំឡើយ។ ដូច្នេះកង្វះខាតលើមណ្ឌលសុខភាពគឺជាកត្តាសំខាន់ ប៉ុន្តែបើពិនិត្យទៅលើស្តង់ដានៃការបង្កើតមណ្ឌលសុខភាពមានកំរិតខ្ពស់ហើយនៅរយះពេលខាងមុខយើងមិនអាចបង្កើតបានជាគោល ការណ៍បើពិនិត្យទៅលើប៉ុស្តិ៍សុខភាពឃើញថាពុំទាន់មានគ្រប់គ្រាន់ដើម្បី ជួយសំរាលដល់ការលំបាកលើផ្នែកទាំសុខភាពក្នុងមូលដ្ឋាន។

### ខ.ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំសាមគ្គីបច្ចុប្បន្ននៅតែជាបញ្ហាចំបងនៅឡើយព្រោះថាចំពោះអណ្តូង ទឹកនិងស្រះទឹកនៅក្នុងឃុំដែលបានសាងសង់ពីមុននោះមួយចំនួនត្រូវបានខូចខាតដូច្នេះជាជំហ៊ានដំបូងនៃការអភិវឌ្ឍន៏ត្រូវស្តារ និងជួសជុល នូវប្រភពទឹកស្អាតទាំងនេះ ហើយជាផែនការនៅពេលអនាគត ឃុំត្រូវបន្ថែមនូវ គម្រោងផែនការក្នុង ការជីកស្រះស្តុកទឹកស្អាត និងអណ្តូងទឹកស្អាត ព្រមទាំងផ្តល់ជូនធុងចម្រោះ ។

- ដើម្បីធានាបាននូវការប្រើប្រាស់ទឹកស្អាត សំរាប់ប្រជាជននៅក្នុងឃុំសាមគ្គីទាំងមូល នោះឃុំមានគម្រោងផែនការកសាងនូវបរិក្ខារទឹកស្អាតដែលរួមមានអណ្តូងលូចំនួន០៣អណ្តូង ។

### ២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា

នៅក្នុងការអភិវឌ្ឍន៏ទៅលើផ្នែកវប្បធិមជាកត្តាមួយចូលរួមចំណែកជំរុញ អោយមានសទ្ទះដល់ការអប់រំ ផ្នែកព្រះពុទ្ធសាសនា ។ រាល់ទីតាំងនីមួយៗតាមបណ្តាភូមិ ត្រូវបានផ្តល់លទ្ធភាព និងជួយសំរួល ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ផ្តាល់មាន ឱកាសចូលរួម ពង្រីកលើការ ផ្សព្វផ្សាយ តាមរយៈការអប់រំដល់ យុវជន ដែលជា សរសរទ្រូង នៃប្រទេសជាតិ អោយជៀសផុសពី អំពើខុសច្បាប់ទាំងឡាយ ដែលរដ្ឋាភិបាលបានកំណត់ ។ ជាអាទិភាពសំរាប់ឃុំសាមគ្គីបច្ចុប្បន្ន សំរាប់កន្លែង គោរព ប្រពៃណីសាសនា នៅថ្ងៃអនាគត ពុំទាន់មានតម្រូវ ការបន្ថែមទេ ។

<u>តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា</u>

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាឆទាន | 0 | 0 | 0 |
| ទីកន្លែងសាការៈបូជា | 0 | 0 | 0 |
| វត្តអារាម | ០១ | ០១ | 0 |
| ផ្សេងៗ | | | |

### ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

ផ្អែកតាមស្ថានភាពជាក់ស្តែងនៃបរិមាណផ្លូវដែលមានក្នុងឃុំសាមគ្គី ឃើញថា ផ្លូវមួយចំនួនត្រូវធ្វើការកែលំអរ ដូចជា ផ្លូវគ្រួសក្រហម ដែលបានសាងសង់ពីមុនមកបច្ចុប្បន្នត្រូវបានខូច ហើយនៅក្នុង ឆ្នាំ ២០០៩ នេះឃុំបានធ្វើការជួសជុលឡើងវិញបាន ១ ខ្សែ ប្រវែងសរុប ១.៥ គីឡូម៉ែត្រ ហើយនៅសល់ពីនោះមានផ្លូវតូចៗចំនួន ៤ ខ្សែទៀតទៅកាន់ភូមិ នីមួយៗមានប្រហែល ២១ គីឡូម៉ែត្រ ។

# ជំពូក ៣

## ផែនការប្រើប្រាស់ដីពេលអនាគត ឆ្នាំ ២០០៩ ដល់ ២០២២

## ៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុងឃុំសាមគ្គីធនធានដែលមានស្រាប់អាចផ្តល់នូវសក្តានុពលភាពដល់ការប្រើប្រាស់ និងអភិរក្ស អភិវឌ្ឍន៍ទៅលើធនធានទាំងនោះអោយមាននិរន្តរភាព ដែលក្នុងនោះរួមមានដូចជា : ស្ថានភាព ដីក្រហម និង ដីខ្មៅសបាគមន៍ ព្រៃឈើ តំបន់ការពារប្រភពទឹក គឺជាបរិស្ថានធម្មជាតិ ដ៏ល្អប្រសើរសំរាប់មជ្ឈដ្ឋានដែលស្ថិតជុំវិញរស់នៅ នៃធម្មជាតិក្នុងតំបន់នោះ ។ នៅក្នុងក្របខណ្ឌនៃការរស់នៅរបស់ពពួកភាវៈរស់ គឺជាបណ្តាញនៃប្រពន្ធ័អេកូឡូស៊ីនៅក្នុងមជ្ឈដ្ឋានព្រៃឈើដែលបានផ្តល់នូវសារៈប្រយោជន៏អោយគ្នាទៅវិញទៅមកជាអាទិ៍មាន ព្រៃផ្តល់នូវទីជំរកដល់ពពួក ភាវៈរស់និងសត្វផ្សេងៗដែលរស់នៅក្នុងព្រៃ ហើយពពួកសត្វសំខាន់ៗ គឺ ឈ្លូស អណ្តើក កន្លាយ ពស់ ទោច ស្វា ត្រកួត អន្សង ឆ្មាបាល និង សត្វជាច្រើនប្រភេទទៀត ។ ចំពោះស្ថានភាពដីជាប្រភេទដីក្រហម និង ដីខ្មៅដែលមានសក្តានុពលយ៉ាងសំខាន់សំរាប់ដាំដំណាំ កសិឧស្សាហ៍កម្ម បានយ៉ាងល្អប្រសើរ ។ តំបន់ការពារប្រភពទឹក ជាតំបន់ដែលមានសារៈសំខាន់ណាស់ ដើម្បីការរស់នៅរបស់ប្រជាពរដ្ឋសំរាប់ផ្គត់ផ្គង់ប្រចាំថ្ងៃអោយមាននិរន្តភាពត្រូវការពារ ព្រៃប្រភពទឹក ដែលជាធនធានធម្មជាតិ ចាំបាច់បំផុតសំរាប់ប្រជាជន ដែលរស់នៅទីនោះ ក៏ដូចជាជនជាតិដើមភាគតិច ជាដើម ។

ទាំងនេះគឺជាសក្តានុពលមួយ ដែលផ្តល់នូវសារៈប្រយោជន៍ ដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនសំរាប់ចិញ្ចឹមជីវភាពនៃការរស់នៅប្រចាំថ្ងៃអោយបានគ្រប់គ្រាន់ និងសមរម្យ ។

### ៣.១.២ តម្រូវការដីតាមប្រភេទ

អត្រាកំណើនប្រជាពលរដ្ឋ គឺជាការកើនឡើងនូវតម្រូវការនៃការប្រើប្រាស់ ទៅលើធនធាន ដូច្នេះយើងត្រូវតែធ្វើការពិចារណាទៅលើធនធានដែលមាននៅក្នុងឃុំ។ ផ្អែកទៅតាមអត្រាកំណើនខាងលើ ឃុំបានរៀបចំរួចហើយនៅផែនការគម្រោងលើតម្រូវការពង្រីកដីភូមិ ដោយបានកំណត់ទៅលើផ្ទៃដីស្ថិតនៅតាមសងខាងបណ្តោយផ្លូវ និងតាមបណ្តោយប្រភពទឹកយ៉ាងត្រឹមត្រូវហើយច្បាស់លាស់ទៅលើដីដែលបានប្រើប្រាស់នោះគឺជាដីចំការពនេចរ នៅក្នុងគោលការអនាគតឃុំសាមគ្គីបានគ្រោងដីសំរាប់ពង្រីកដីភូមិ សំរាប់រយៈពេល ១៥ឆ្នាំ ហើយក្នុងការពង្រីកផ្ទៃដីលំនៅដ្ឋានតាមប្រភពទឹកប្រសិនបើពុំមានការរៀបចំអោយបានត្រឹមត្រូវទេនោះ វានិងបណ្តាលអោយមានការប៉ះពាល់ដល់តំបន់ព្រៃឈើ ។

ព្រៃកប់ខ្មោច ឃុំពុំមានលទ្ធភាពក្នុងការពង្រីកដីសំរាប់កប់ខ្មោចទេតែវាជាគោលការណ៍ឃុំមានរៀបចំនៅលើដីកប់ខ្មោច ចាស់ដែលជាប្រភេទដីព្រៃរេចរិលហើយនៅតាមភូមិនីមួយៗ ។

នៅក្នុងការពង្រីកដីស្រែវស្សា របស់ឃុំសាមគ្គី គឺត្រូវបានចាប់អារម្មណ៏ទៅលើ ដីចំការដែលបានបោះបង់ចោល

ក្លាយទៅជាវាលស្មៅ ដែលក្នុងនោះតាមគោលការណ៍ដែល ឃុំបានគ្រោងទុកសំរាប់ការពង្រីកដីស្រែចំនួន ១១៤ ហ.ត នៅតាមមាត់អូរ ឬច្រប់ដែលជាប្រភពទឹកព្រោះស្ថានភាពភូមិសាស្ត្រតំបន់នោះជាតំបន់ខ្ពង់រាបពុំអាចមានលទ្ធភាពសាងសង់ ប្រពន្ធ័ ធារាសាស្ត្របានឡើយ ។

តារាងតម្រូវការនៃការប្រើប្រាស់ដីអនាគត

| ការប្រើប្រាស់ដីធ្លី | ក្រឡាផ្ទៃឆ្នាំនេះ( ហិកតា) | ក្រឡាផ្ទៃ១៥ឆ្នាំ( ហិកតា) | បំរែបំរួល ( ហិកតា) |
|---|---|---|---|
| ចំការបោះបង់ដុះស្មៅ | 0.៤៨ | 0.៤៨ | 0 |
| ចំការបោះបង់ដុះព្រៃគម្ពោធ | ៩១៣ | ៩១៣ | 0 |
| កន្លែងកប់ខ្មោច | ៥ | ៥ | 0 |
| ព្រៃស្រោងសើម | ២៣០៦ | ២២៤៩ | -៥៧ |
| វាលស្មៅ | ២០៧ | ២០៧ | 0 |
| វាលភក់ | ២២ | ២២ | 0 |
| ព្រៃចំរុះ( ស្រោង និងរបោះ) | ១០៥៥ | ១០៥៥ | 0 |
| ចំការឈើហូបផ្លែ | ១៦៧ | ១៦៧ | 0 |
| ចំការកៅស៊ូ | ៥ | ៥ | 0 |
| ព្រៃដុះឡើងវិញ | ៩៩៥ | ៩៦៦ | -២៩ |
| ព្រៃគម្ពោធ | ១០២ | ១០២ | 0 |
| ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ២០៩ | ២០៩ | 0 |
| ដីកសិកម្មពនេចរ | ១១៣៨ | ១១២៣.៨១ | -១៤.១៩ |
| ស្រូវវស្សា | 0 | ១១៤.៦៨ | ១១៤.៦៨ |

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរអំពើ

ការគ្រប់គ្រង និងបែងចែកសំរាប់ការប្រើប្រាស់ដី មានកត្តាដែលធ្វើអោយមានការផ្តល់នូវ ផលប្រយោជន៍ និង មាននិរន្តរភាពហើយ នឹងមានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និង បរិស្ថាន ដែលក្នុងនោះមានដូចជា :

ការប្រែប្រួលពីព្រៃដុះឡើងវិញទៅជាដីលំនៅដ្ឋាន សំរាប់ការរស់នៅនេះជាការ ពង្រីកទីប្រជុំជនភូមិទៅតាមកំណើនរបស់ប្រជាពរដ្ឋ បច្ចុប្បន្ន។ វាជាកត្តាអំណោយផល ដល់ការបង្កើននូវការសាងសង់លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក្នុងគោលដៅអភិវឌ្ឍន៍មូលដ្ឋាន ។ នេះជាការប្រែប្រួលប្រភេទដីប្រសិនបើព្រៃដុះឡើងវិញដែលជាដី ត្រូវបោះបង់ចោលហើយព្រៃនោះពុំមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចនោះវាជាការប្រសើរសំរាប់ការពង្រីកលើតំបន់លំនៅដ្ឋាន។ តែក្នុងករណីព្រៃដុះឡើងវិញ មានសក្តានុពលធនធានព្រៃឈើ និង ធ្វើអោយមានការប៉ះពាល់ដល់ធនធានធម្មជាតិ និងបាត់បង់នូវប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ នៅក្នុងឃុំនេះរួមទាំងប៉ះពាល់ដល់ជីវភាពរស់នៅរបស់គាត់ដែលពឹងផ្អែកលើផល-អនុផលព្រៃឈើ និង ការបរបាញ់សត្វព្រៃជាលក្ខណៈគ្រួសារតាមប្រពៃណី ។

ចំពោះការប្រែប្រួលពីដីចំការបោះបង់ចោល ទៅជាដីស្រែវស្សា ជាលក្ខណៈអំណោយផលដ៏ល្អក្នុងការបង្កើនជីវភាពរស់នៅបានមួយកំរិតថែមទៀតដល់ប្រជាពលរដ្ឋដែលរស់ឃុំសាមគ្គី ។

ការពង្រីកវិស័យអប់រំដោយផ្តោតទៅលើ ការពង្រីកអាគារសិក្សា និងសាលា គឺជាការចាំបាច់បំផុតសំរាប់ការបង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន។ បច្ចុប្បន្នឃុំមានដីបំរុងគ្រប់គ្រាន់ សំរាប់សាងសង់សាលារៀនថ្មី សំរាប់ថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ សូម្បីតែទីតាំងនៅតាមសាលាចាស់ ក៏មានដីដែលអាចសាងសង់អាគារសិក្សាបន្ថែមបានដែរ។ រីឯសាលាមតេយ្យ ដោយមើលឃើញការលំបាកសំរាប់កុមារ ដែលគ្មានលទ្ធភាពក្នុងសិក្សានៅទីកន្លែងឆ្ងាយ គឺជាអាទិភាពឃុំ ត្រូវព្យាយាមរកដំណោះស្រាយអោយខានតែបាននៅតាមបណ្តាភូមិ គោលដៅព្រោះវាមានសារៈសំខាន់និងជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាលនិងការបំពាក់បំប៉នចំណេះដឹងដល់អនក្ខរៈជនក្នុងមូលដ្ឋាន។ ដោយឡែកការពង្រីកវិស័យសុខាភិបាលគឺផ្តោតសំខាន់លើការសាងសង់ ប៉ុស្តិ៍សុខភាពជាចំបង ។ វាមានសារៈសំខាន់ផ្នែកសេវាសុខភាពប្រជាពរដ្ឋក្នុងឃុំ ពីព្រោះបច្ចុប្បន្ននៅក្នុងឃុំឯកភាពពុំទាន់មាននៅឡើយទេ។

### ៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត

### ៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី

ការប្រើប្រាស់ដីនៅក្នុងឃុំសាមគ្គី ត្រូវបានបែងចែកទៅតាមគោលការណ៍មួយចំនួនដែលមានលក្ខណៈជាសត្យានុម័តហើយបានអនុលោមទៅតាមមុខនាទីដូចខាងក្រោមៈ

**១. ស្រូវវស្សា :**

**-ក្បាលដី ២១១០ :** ផ្ទៃដីស្រូវវស្សាសរុបនៅក្នុងឃុំសាមគ្គីពេលអនាគតគឺចំនួន ១១៤.៦៨ ហិកតាប្រជាពលរដ្ឋក្នុងឃនេះធ្វើស្រែអាស្រ័យទៅលើទឹកភ្លៀងធ្លាក់ភាគច្រើនការធ្វើស្រែរបស់គាត់គឺដាំស្រូវតាមចំការ (បុកដាំ ) ហើយផ្ទៃដីស្រែរបស់គាត់គឺ ការធ្វើលើចំការពនេចរមានចំនួន ១៤.១៩ ហ.ត ព្រៃដុះឡើងវិញចំនួន២៩ ហ.ត និងព្រៃស្រោងចំនួន ៥៧ ហ.ត ។

**២. សហគមន៏ព្រៃឈើ :**

**-ក្បាលដី ៣៧១០ :** ដីត្រៀមបង្កើតសហគមន៏ព្រៃឈើនៅក្នុងឃុំតឺនចំនួន២កន្លែងសរុបចំនួន២២៨,៨១ ហ.ត ដែលបងប្អូនប្រជាសហគមន៏បាន និងកំពង់ធ្វើពាក្យស្នើសុំទៅក្រសួងកសិកម្ម(រដ្ឋបាលព្រៃឈើ)ធ្វើតំបន់ថែរក្សាការពារដើម្បីទុកអោយកូនចៅជំនាន់ក្រោយបានឃើញ និងបានស្គាល់ពិសេសគឺសំរាប់រុករកបន្លែបង្ការយកមកផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ផងដែរប៉ុន្តែនៅក្នុងតំរោងដីព្រៃឈើសំរាប់ធ្វើតំបន់ការពារគឺមានពាក់ពន្ធ័និងប្រភេទព្រៃស្រោងចំនួន២៨៨.៨១ហ.ត។ :

**តារាងតំបន់ដីប្រើប្រាស់ដីពេលអនាគត**

| ល.រ | ឈ្មោះក្បាលដី | លេខកូដក្បាលដី | ក្រឡាផ្ទៃសំរាប់១៥ឆ្នាំខាងមុខ(ហិកតា) | ចំនួនកន្លែង |
|---|---|---|---|---|
| ០១ | ដីស្រូវវស្សា | F២១១០ | ១១៤.៦៨ | ២ |
| ០២ | សហគមន៏ព្រៃឈើ | F៣៧១០ | ២២៨.៨១ | ២ |
| **សរុប** | | | **៣៤៣** | **៤** |

ឃុំសាមគ្គី ថ្ងៃ ...02...ខែ...04......ឆ្នាំ២០10

**មេឃុំ**

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត
និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវដ្ឋ ខេត្តរតនគិរី

"ដើម្បីមេត្តាពិនិត្យ និងសំរេច"

អូរជុំ ថ្ងៃ ...05...ខែ...04...ឆ្នាំ ២០10

**អភិបាលនៃគណៈអភិបាលស្រុក**

**និងជាប្រធានក្រុមការងារជីវដ្ឋ**

**ស្រុកអូរជុំ**

សាក់ សុន

**បានឃើញ និង ឯកភាព**

រតនគិរី ថ្ងៃ ...21...ខែ...05...ឆ្នាំ ២០10

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវដ្ឋ**

**ខេត្តរតនគិរី**

ពៅ ហមផាន

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖  ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ២៖  ស្ថានភាពនៃការគ្រប់គ្រង  និងកាន់កាប់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ៣៖  បញ្ហាពាក់ពន្ធ័ក្នុងការប្រើប្រាស់ដី

ឧបសម្ព័ន្ធ៤៖  ក្រុបខ័ណ្ឌនៃការអភិវឌ្ឍន៍

ឧបសម្ព័ន្ធ៥៖  បញ្ជីគំរោង

ឧបសម្ព័ន្ធ៦៖  ផែនទីប្រើប្រាស់ដីលំអិតនៅក្នុងឃុំ

ឧបសម្ព័ន្ធ៧៖  ផែនទីប្រើប្រាស់ដីសាមញ្ញនៅក្នុងឃុំ

ឧបសម្ព័ន្ធ៨៖  ផែនទីប្រើប្រាស់ដីអនាគតនៅក្នុងឃុំ  ឆ្នាំ២០០៩-២០២២

# ឧបសម្ព័ន ១

# ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

- **ដីលំនៅដ្ឋានភូមិ:**

**ដីភូមិលាយសួនដំណាំ :**

ដីភូមិលាយសួនដំណាំ នៅក្នុងមូលដ្ឋានឃុំសាមគ្គី គឺជាដីស្ថិតនៅតាមដងផ្លូវ ដែលមានស្ថានភាពជាដីទីជំរាល និង ដោយការចាក់បំពេញធ្វើជាភូមិដ្ឋាន ។ ជាមួយគ្នានេះដែរដីភូមិទាំងនេះត្រូវបានដាំនូវដំណាំរួមផ្សំនានាជាច្រើន ដូចជាស្វៃ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ ខ្ញី ជី ត្រប់ ម្រិច ចេក ដូង ដំឡូង ស្វាយ ខ្នុរ អំពៅ និងដំណាំរួមផ្សំមួយចំនួនទៀត........។ ល ។ ដំណាំភាគច្រើនស្ថិតនៅ ជាប់តគ្នា តាមបណ្តោយផ្លូវ ។ ដីលំនៅដ្ឋាននីមួយៗមានទំហំក្បាលដី ចាប់ពី ១៥មែត្រ x ៥០ ម៉ែត្រ ទៅ ៣០ ម៉ែត្រ x ១០០ ម៉ែត្រ ។ លំនៅដ្ឋាននៅឃុំនេះជាប្រភេទលំនៅដ្ឋានចំរុះឈើ (ប្រភេទឈើអារ) ប្រកសង្កសី ស្លឹក ខ្លះសង់ជាប់នឹងដី ខ្លះខ្ពស់ផុត ពីដីតាមបែបទំនៀមទំលាប់ប្រពៃណីខ្មែរនិងបងប្អូនជនជាតិដើមភាគតិចនៅទីនោះ។ ប្រភេទដីភូមិលាយ សួនដំណាំរបស់បងប្អូនជនជាតិដើមភាគតិចក៏មានសង់ផ្ទះនៅតាមចំការរបស់គាត់ដែរ តែភាគតិចណាស់ប្រហែល ១% នៃបងប្អូនតែប៉ុណ្ណោះ ។ ដីភូមិលាយសួនដំណាំភាគតិចច្រើនតែកសិករដាំដំណាំនៅចំការឆ្ងាយពីភូមិ ពី៣-៤ គីឡូម៉ែត្រពីភូមិទៅចំការ ។

- **កន្លែងកប់ខ្មោច :**

កន្លែងកប់ខ្មោចនៅឃុំសាមគ្គី ភាគច្រើនជាដីដែលពុំសូវមានប្រភេទឈើធំៗឬព្រៃក្រាស់នោះទេ វាសំបូរកូនឈើតូចៗដែលការប្រើប្រាស់ធនធានទាំងនោះពុំមែនជាប្រយោជន៍ធំដុំរបស់ប្រជាជនឡើយ ។ដីកប់ខ្មោច សំរាប់តែបញ្ចុះសពតាមប្រពៃណីនៃជនជាតិដើមភាគតិចនៅក្នុងតំបន់ដែលពួកគេពុំមានការប្រកាន់ភ្ជាប់នូវប្រពៃណីណាផ្សេងទៀតក្រៅពីការកាន់នូវ ព្រហ្មញ្ញសាសនាដែលមានតាំងពីដូនតាមក ។

- **ដីស្រូវវស្សា :**

ដីភូមិលាយស្រែ គឺជាដីដែលភាគច្រើនជាដីនៅដាច់ៗពីគ្នា ដែលពួកគាត់សង់លំនៅដ្ឋាននៅជាប់ជាមួយស្រែហើយពួគគាត់តែងតែធ្វើសំណាបនៅក្បែរផ្ទះ ហើយដីស្រែទាំងនោះមិនអាចធ្វើអ្វីបានក្រៅពីធ្វើស្រែវស្សាតែមួយរដូវតែប៉ុណ្ណោះ និងដំណាំរួមផ្សំដូចជា ស្លឹកគ្រៃ ពោះគ្រីវ ត្រប់ ត្រឡាច ល្ពៅ ស្ពៃ ហើយដីស្រែទាំងនេះភាគច្រើនមួយគ្រួសារ ១ ហិកតា ទៅ២ហិកតា (តែមិនគ្រប់គ្រួសារ) ហើយនៅពេលផុតរដូវធ្វើស្រែពួកគាត់វិលត្រលប់មករស់នៅក្នុងភូមិវិញ ។ ដូច្នេះតាមការពិនិត្យសក្តានុពលនៃការប្រើប្រាស់ ដីឃើញថាគ្មានតុល្យភាពទៅនិងកំណើននិងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋឡើយ គឺបង្កើនផលិតភាព លើវិស័យកសិកម្មអោយបានល្អប្រសើរជាងមុន ( បញ្ចូល បច្ចេកវិទ្យាថ្មី ) ។

- **ដីកសិកម្មពនេចរ :**

ដីកសិកម្មពនេចរនៅក្នុងឃុំសាមគ្គីជាដីចំការផ្លាស់វេនដែលមានទំហំ ១១៣៨ហិកតា ដំណាំដែលក្នុងនោះរួមមានចំការដំណាំស្រូវចំការនិងដំណាំរួមផ្សំផ្សេងៗទៀតរួមមានបន្លែបង្កាគ្រប់ប្រភេទ និងមិនមានអោយដាំដំណាំដើមឈើហូបផ្លែនិងដំណាំយុទ្ធសាស្ត្រទេ ព្រោះដីចំការវិលជុំនេះពួកគាត់ធ្វើតែរយៈពេល២ឆ្នាំប៉ុណ្ណោះ ដែលក្នុងឆ្នាំទី១ដំណាំស្រូវទទួលបាន ទិន្នផលខ្ពស់ ចំណែកនៅឆ្នាំទី២ ផលស្រូវថយចុះបើធៀបនឹងឆ្នាំទី១។ បន្ទាប់ពីនោះគឺពួកគាត់បន្តទៅធ្វើនៅកន្លែងផ្សេងទៀតដែលដីនោះ បានបោះបង់អស់រយៈពេល៥ឆ្នាំមុននេះបានក្លាយជាដីដុះដើមឈើឡើងវិញនិងមាន ជីវៈជាតិ ។

ដីកសិកម្មពនេចរគឺសំរាប់បងប្អូនជនជាតិភាគតិចដែលការគ្រប់គ្រងនិងកាន់កាប់ទៅតាមជំនឿ និងប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៏។ ចំការប្រភេទនេះច្រើនកាប់នៅចំងាយពី២គ.មទៅ៣គ.មពីភូមិ ហើយចំការប្រភេទនេះពេលអនាគតនឹងក្លាយទៅជាដីលំនៅដ្ឋានអចិន្ត្រៃយ៏របស់ប្រជាពលរដ្ឋនៅក្នុងឃុំ។

- **ព្រៃស្រោងស្ងួត :**

ព្រៃស្រោងស្ងួតនៅក្នុងឃុំសាមគ្គីមានទំហំ ២៣០៦ ហិកតាជាប្រភេទព្រៃញ៉ាតមានឈើធំៗនិងមានច្រើនស្រទាប់ហើយប្រភេទដើមឈើរក្សានូវស្លឹករបស់វាពេញមួយឆ្នាំ ។ ព្រៃប្រភេទនេះរួមបញ្ចូលទាំងព្រៃតំបន់ទំនាបត្រូពិច ព្រៃបៃតងតំបន់ភ្នំ ព្រៃបៃតងស្ងួត និងមានគំរបព្រៃក្រាស់ៗដែលអាចរក្សាបានសំណើមបានយូរ ។

- **ព្រៃចំរុះ( ស្រោង និងរបោះ) :**

ព្រៃចំរុះ (ស្រោង និងរបោះ)នៅក្នុងឃុំសាមគ្គីមានទំហំ ១០៥៥ ហិកតាព្រៃប្រភេទនេះជាការរាប់បញ្ចូលព្រៃស្រោង និងប្រភេទឈើនៃព្រៃរបោះ ហើយភាគរយនៃព្រៃស្រោង ប្រែប្រួលពី ៣០% ទៅ ៧០% ។ ព្រៃចំរុះមានពណ៌បៃតងពេញមួយឆ្នាំទោះបីជាព្រៃរបោះមានច្រើនលើសលប់ក៏ដោយ ។

- **ព្រៃដុះឡើងវិញ :**

ប្រភេទព្រៃដុះឡើងវិញនៅក្នុងឃុំសាមគ្គីមានទំហំ៩៩៥ហិកតាព្រៃដុះឡើងគឺជាព្រៃដែលបានកាប់ឬរិចរិលហើយត្រូវបានដុះឡើវិញដោយស្រទាប់កូនឈើតូចៗដែលដុះឡើងវិញជាថ្មីម្តងទៀតបន្ទាប់ពីបានកាប់រានធ្វើចំការពនេចរអស់មួយរយៈពេលមកអាចនិយាយបានថាជាតំបន់នៃដំណុះព្រៃចាស់ៗឡើងវិញ និងមានពិណខៀវខ្ចី។

- **វាលស្មៅ :**

ដីប្រភេទវាលស្មៅនៅឃុំសាមគ្គីមានទំហំ ២០៧ ហិកតាដែលជាប្រភេទដីស្រែដែលគេបានបោះបង់ចោល ដីប្រភេទនេះ ពុំសូវសំបូរទៅដោយជីជាតិច្រើនទេ តែវាអាចទាក់ទាញនូវប្រភេទសត្វព្រៃដែលចូលចិត្តរស់នៅព្រោះជាកន្លែងសំបូរចំណីអាហារ តែងាយរងគ្រោះដោយភ្លើងឆេះនៅរដូវប្រាំង ។

- **ចំការបោះបង់ដុះស្មៅ :**

ចំការបោះបង់ដុះស្មៅមានទំហំផ្ទៃដីនៅក្នុងឃុំសាមគ្គីសរុប ០.៤៣ A ហើយភាគច្រើនប្រជាពលរដ្ឋមាន ទំលាប់ហៅថា ព្រៃបូសដែលបានធ្វើចំការកាលពីមុននឹងបានបោះបង់ចោលទុកអោយដុះស្មៅនិងដំណុះព្រៃឡើងវិញដូចជាព្រៃ តឿជាដើម ។

- **ចំការបោះបង់ដុះព្រៃគម្លោច :**

ចំការបោះបង់ដុះព្រៃគម្លោចដែលមានទំហំ ៩១៣ ហិកតា គឺជាដីមិនមែនព្រៃដែលរួមមានព្រៃគម្លោច បៃតងជានិច្ច និងព្រៃគម្លោចស្ងួត។ ព្រៃគម្លោចបៃតងជានិច្ច ជាការដុះលាយនៃពពួកចុល្លព្រឹក្សក្រាស់ វាលស្មៅ និងដើមឈើដែលគំរបកន្សោមស្លឹកក្រោម២០%។ ព្រៃប្រភេទនេះឃើញមានភាគច្រើននៅតំបន់ដីរាក់ៗ នៅលើ កំពូលភ្នំក្រោមលក្ខខ័ណ្ឌអាកាសធាតុ ឬជាលទ្ធផលនៃការប្រើប្រាស់ដីមិនមាននិរន្តរភាព ។ ព្រៃប្រភេទនេះអាច ក្លាយទៅជាព្រៃធំៗឡើងវិញបាន។

- **ព្រៃគម្លោចលាយដើមឈើធំមួយៗ :**

ព្រៃគម្លោចលាយដើមឈើធំមួយៗមានទំហំ ២០៩ហិកតាជាប្រភេទដីដែលដុះស្មៅដែលមានពណិស្រស់ បំព្រងនៅរដូវវស្សា និងអស់សោភ័ណ្ឌភាពនៅរដូវប្រាំងចូលមកដល់ ព្រៃប្រភេទនេះក៏មានដើមឈើធំមួយៗ ដែលសំបូរទៅដោយ ពពួកថ្មតូចៗ និងព្រៃគម្លោចពណិបៃតងជានិច្ច និងព្រៃគម្លោចស្ងួត ។

- **វាលភក់ :**

វាលភក់នៅក្នុងឃុំសាមគ្គីមានទំហំសរុប ២២ ហិកតា តំបន់នេះមានទឹកដក់នៅរដូវវស្សា និងនៅរដូវប្រាំង តំបន់នោះខ្លះស្ងួតហួតហែង ខ្លះអាចមានទឹកដក់តិចៗ ដែលអាចជួយទ្រទ្រង់ ទៅដល់ពពួកសត្វព្រៃមករកស៊ី និងលេង ។ ដី វាលភក់ជាដីដែលពុំមានជីជាតិទេ តែវាមានទំនាក់ទំនង និងការបំពេញអោយគ្នាទៅវិញទៅមក ជាមួយសត្វ ក៏ដូចជាជីវៈចំរុះ គ្រប់ប្រភេទដែលមាននៅតំបន់នេះ ។

| | | |
|---|---|---|
| ១ | Code : 1200<br>**ដីលំនៅដ្ឋានភូមិលាយសួនដំណាំ** |  |

| | | |
|---|---|---|
| ២ | Code : 1210<br>កន្លែងកប់ខ្មោច |  |
| ៣ | Code : 2110<br>ស្រូវវស្សា |  |
| ៤ | Code : 2400<br>ដីកសិកម្មពនេចរ |  |

| | | |
|---|---|---|
| ៥ | Code : 3220<br>ព្រៃស្រោងស្ងួត |  |
| ៦ | Code : 3210<br>ព្រៃរបោះ |  |
| ៧ | Code : 3300<br>ព្រៃចំរុះ (ស្រោង និងស្ងួត) |  |

| | | |
|---|---|---|
| ៨ | Code : 3400<br>ព្រៃដុះឡើងវិញ |  |
| ៩ | Code : 4100<br>វាលស្មៅ |  |
| ១០ | Code : 4110<br>ចំការបោះបង់ដុះស្មៅ |  |

| | | |
|---|---|---|
| ១១ | Code : 4510<br>ចំការបោះបង់ដុះព្រៃគម្ពោធ |  |
| ១២ | Code : 3310<br>ព្រៃដុះតាមមាត់ទឹក |  |
| ១៣ | Code : 4600<br>ព្រៃគម្ពោធលាយដើមឈើធំមួយៗ |  |

| | | |
|---|---|---|
| ១៤ | Code : 5300<br>វាលភក់ |  |

# ឧបសម្ព័ន្ធ ២

# ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន (ផែនទីA-3)

| លរ | ប្រភេទនៃការប្រើប្រាស់ដី | ទំហំ ( ហត) | | ចំណាត់ថ្នាក់របស់មូលដ្ឋាន |
|---|---|---|---|---|
| | | គម២ | ហត | |
| ១ | ដីលំនៅដ្ឋានភូមិ | ១២១០៧៣ | ១៣ | ផ្ទះ-ឈើហូបផ្លែ |
| ៤ | ដីកសិកម្មពនេចរ | ២៣៣២១៨ | ២៣៣ | ដីចំការផ្លាស់វេន |
| ៥ | ព្រៃស្រោងសើម | ១០៦២៦០៣ | ១០៦ | ព្រៃញាតមានឈើធំៗ |
| ៩ | ព្រៃដុះឡើងវិញ | ១១២៧៣០០៥ | ១១២៧ | ព្រៃកម្ពោធ |
| ១០ | វាលស្មៅ | ៨៧១២១០ | ៨៧ | ស្រែបោះបង់ |
| ១១ | ចំការបោះបង់ដុះស្មៅ | ១៣៦៥៨៨២៧ | ១៣៦៦ | ព្រៃប្ញូស |
| ១៣ | ចំការកៅស៊ូ | ៤២៤២ | ០ | ចំការកៅស៊ូ |
| ១៥ | ចំការហូបផ្លែ | ៣២៣៥៤៩០ | ៣២៣ | សួនដំណាំហូបផ្លែ |
| | សរុប | ៣២៥៥៨៥៧៨ | ៣២៥៥៨៥៧៨ | |

ប្រភព : ទិន្នន័យ GIS ប្រមូលពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្តរតនគីរី

# ឧបសម្ពន្ធ័ ៣

## បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី (បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៤ |
| **គ្មានជំនាញ និងពូជ** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-ខ្វះជំនាញ និងពូជកៅស៊ូដាំជាលក្ខណ:គ្រួសារ | ក-១-គម្រោងស្នើសុំផ្តល់កូនកៅស៊ូ<br>ក-២-បច្ចេកទេសដាំដំណាំកៅស៊ូ |
| **ខ្វះម្ហូបបរិភោគជីវភាពក្រីក្រ** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-គ្មានជំនាញនិងពូជ | ក-១-ផ្តល់ពូជបន្លែគ្រប់<br>ក-២-ផ្តល់ពូជជ្រូក.មាន.ទា<br>ក-៣-ផ្តល់ពូជគោ/ក្របី<br>ក-៤-ផ្តល់ពូជឈើហូបផ្លែ<br>ក-៥-ជីស្រែះចិញ្ចឹមត្រី<br>ក-៥-ផ្តល់ពូជត្រិ |
| **ខ្វះទឹកស្អាតប្រើប្រាស់** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-អណ្តូងតិចប្រជាចនច្រើន | ក-១ ជីកអណ្តូងលូ |
| **កុមារគ្រប់អាយុមិបានចូលរៀន** | ភូមិអូម | ក-គ្មានសាលារៀន | ក-១-សាងសង់សាលារៀន |
| **គ្មានប៉ុស្តិ៍សុខភាព** | ភូមិប៉អរ | ក-នៅឆ្ងាយពីមណ្ឌលសុខភាព | ក-១-បង្កើតប៉ុស្តិ៍សុខភាព |

| | | | |
|---|---|---|---|
| **ភាគរយស្ត្រីមានគ្រោះថ្នាក់ពេលសំរាល់កូនខ្ពស់** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-ខ្វះការយល់ដឹងពីការថែរក្សាសុខភាពពេលមានផ្ទៃពោះ | ក-១-ជំរុញសកម្មភាពទទួលយកសេវាសុខភាពស្ត្រីមានផ្ទៃពោះ ។<br>ក-២-បណ្តុះបណ្តាលពង្រឹងសមត្ថភាពឆ្មបបុរាណភូមិ និងផ្តល់សំភារៈ( កញ្ចប់សំរាប់សំរាលកូន) ។ |
| **ស្ត្រីនិងកុមារមានជំងឺឆ្លង** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-ខ្វះការចាក់ថ្នាំការពារ | ក-១-ផ្តល់ការចាក់វ៉ាកសាំងស្ត្រី និងកុមារ |
| **កើតមានជំងឺអេដស៏** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-មិនទាន់យល់ពីវិធីការពារ | ក-១-អប់រំផ្សព្វផ្សាយអំពីជំងឺអេដស៏ |
| **ភាគរយសិស្សបោះបង់សាលារៀន** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-គ្រួសារមានជីវភាពក្រីក្រ | ក-១-ជំរុញឪពុក ម្តាយនាំកូនចូលរៀន |
| | | | ក-២-ផ្តល់អាហារូបករណ៏ដល់សិស្សក្រីក្រ |
| **បាត់បង់ព្រៃឈើ** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-ការកាប់ព្រៃធ្វើចំការថ្មី ចំនួនប្រជាជនកើនឡើង | ក-១-ពង្រឹងគណៈកម្មកាគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន |
| | | | ក-២-បង្កើតសហគមន៏ព្រៃឈើ |
| | | | ក-៣-ផ្តល់ពូជកូនឈើ |
| | | | ក-៤-បច្ចេកទេសដាំកូនឈើ |
| **ខ្វះការយល់ដឹងពីច្បាប់** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-ការយល់ដឹងនៅមានកំរិត | ក-១-ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ |
| | | | ក-២-អប់រំផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រី និងកុមារ |
| **អសន្តិសុខក្នុងសង្គម** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-មានចោរលួចទ្រព្យប្រជាជន | ក-១-ពង្រឹងការសន្តិសុខ និងច្បាប់ចោរកម្ម |
| **មានអំពើហិស្សាក្នុងគ្រួសារ** | ប៉អរ.ប៉ជន.អូម.ក្រូច | ក-មិនទាន់យល់ដឹងពីតួនាទីយេនឌ័ | ក-១-អប់រំផ្សព្វផ្សាយច្បាប់អំពើរហិស្សាក្នុងគ្រួសារ |

| | | | |
|---|---|---|---|
| **ស្ត្រីមេម៉ាយ និងកុមារច្រើន** | ប៉អរ.ប៉ាជន.អូម.ក្រួច | ក-ប្តីស្លាប់/ប្តីលែង | ក-១-ផ្តល់ឥណទានសាច់ប្រាក់<br>ក-២-ផ្តល់វិជ្ជាជីវៈចំរុហ |
| **ធនធានជលផលថយចុះ** | ប៉អរ.ប៉ាជន.អូម.ក្រួច | ក-នេសាទខុសច្បាប់ | ក-១-អាជ្ញាធរពង្រឹងទប់ស្កាត់បទល្មើសឆក់ត្រី និងបំពុលត្រី |
| **បាត់បង់ និងមានទំនាស់ដីធ្លី** | ប៉អរ.ប៉ាជន.អូម.ក្រួច | ក-កាប់ឈើយកដីធ្វើជាកម្មសិទ្ធ | ក-១-បង្កើតគណៈកម្មការដោះស្រាយទំនាស់ដីធ្លី<br>ក-២-ផ្សព្វផ្សាយច្បាប់រានដីព្រៃធ្វើជាកម្មសិទ្ធ |
| **ប្រជាពរដ្ឋមិនចេះ អក្សរច្រើន** | ប៉អរ.ប៉ាជន.អូម.ក្រួច | ក-មិនយល់ពីប្រយោជន៏នៃ ការសិក្សា | ក-១-ជំរុញប្រជាពរដ្ឋឱ្យយល់ដឹងការសិក្សារៀន និងការរៀនសូត្រ។ |

# ឧបសម្ព័ន្ធ ៤

## ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងវិធីនៃការប្រើប្រាស់ដីធ្លីអនាគត

## កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ (តារាង)

| តម្រូវការនៃ ការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀង នៅលើផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ហូបចុកគ្រប់គ្រាន់ជីវភាពធូធានិងកាន់តែប្រសើរឡើង | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំឯកភាព ស្រុកអូរជុំ ខេត្តរតនគិរី | នៅឆ្នាំ២០០៨ដល់ឆ្នាំ២០១២ប្រជាពលរដ្ឋក្មេងចាស់ប្រុសស្រីមានជីវភាពប្រសើរឡើងតាមរយៈម្ហូបអាហារហូបចុកមានប្រាក់ចំណូលអនុវត្តកសិកម្មចំរុះជាលក្ខណគ្រួសារដាំដំណាំយុទ្ធសាស្ត្រផ្សេងៗ និងមានឱកាសបានចូលរួមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។ | ពង្រីកប្រពន្ធ័កសិកម្មចំរុះ បង្កើនប្រាក់ចំណូលគ្រួសារនិងកែលំអរជីវភាព រស់នៅ | - គម្រោងស្នើសុំផ្តល់កូនកៅស៊ូ<br>- បច្ចេកទេសដាំដំណាំកៅស៊ូ<br>- ប្រពន្ធ័កសិកម្មចំរុះ និងផ្តល់ពូជ<br>- ជីកស្រះចិញ្ចឹមត្រី<br>- ផ្តល់ពូជកូនត្រី | |

| | | | | | |
|---|---|---|---|---|---|
| មានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំឯកភាព ស្រុកអូរជុំ ខេត្តរតនគិរី | នៅឆ្នាំ២០០៨ដល់ឆ្នាំ២០១២ប្រជាពលរដ្ឋក្មេងចាស់ប្រុសស្រីមានជីវភាពប្រសើឡើងតាមរយៈការពង្រឹងពង្រីកសេវាសុខាភិបាលសេវាអប់រំតាមមូលដ្ឋានដើម្បីកាត់ បន្ថយអត្រាគ្រោះថ្នាក់ដោយជំងឺផ្សេៗកុមារគ្រប់អាយុបានចូល រៀន កាត់បន្ថយអត្រាសិស្ស បោះបង់សាលាមានឱកាសបានចូលគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | ពង្រីកនិងពង្រឹងសេវាសុខាភិបាល កាត់បន្ថយអាត្រាគ្រោះថ្នាក់ដោយជម្ងឺផ្សេងៗ | ជីកអណ្តូងលូ | |
| | | | | បង្កើតប៉ុស្តិ៍សុខភាព | |
| មានប៉ុស្តិ៍សុខភាពផ្តល់សេវាទាន់ពេល | | | | - ជំរុញសកម្មភាពទទួលយកសេវាសុខភាពស្ត្រីមានផ្ទៃពោះ<br>- បណ្តុះបណ្តាលពង្រឹងសមត្ថភាពឆ្មបបុរាណភូមិ និងផ្តល់សំភារះ (កញ្ចប់សំរាលកូន)<br>- ផ្តល់ការចាក់វ៉ាកសាំងស្ត្រី និងកុមារ | |
| ជួយគាំពារមាតា និងទារកអោយមានសុខភាពល្អ | | | | អប់រំផ្សព្វផ្សាយអំពីជំងឺអេដស៍ | |
| ទប់ស្កាត់ជំងឺអេដស៍ | | | | | |
| កុមារគ្រប់អាយុបានចូលរៀន | | | ពង្រីកនិងពង្រឹងសេវាអប់រំកាត់បន្ថយអត្រាសិស្សបោះបង់សាលា | សាសង់សាលារៀន | |

| | | | | | |
|---|---|---|---|---|---|
| | | | | - គម្រោងជំរុញឪពុកម្តាយនាំកូនចូលរៀន<br>- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ | |
| សិស្សក្រីក្រមានឱកាសចូលរៀន | | | | | |
| ធនធានធម្មជាតិនៅគង់វង<br>. | ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំឯកភាព ស្រុកអូរជុំ ខេត្តរតនគីរី | នៅឆ្នាំ២០០៨ដល់ឆ្នាំ២០១២ប្រជាពលរដ្ឋក្មេងចាស់ប្រុសស្រីមានជីវភាពប្រសើរឡើងតាមរយៈការយល់ពីសារៈប្រយោជន៍នៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានព្រមទាំងការចូលរួមយ៉ាងសកម្ម ដើម្បីថែរក្សាការពារជាពិសេសការប្រើប្រាស់អោយបានសមស្រប | ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ កាត់បន្ថយការបាត់បង់ និងទំនាស់ | ពង្រឹងគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | |
| នៅមានធនធានជលផលសំរាប់ជីវភាព | | | | អាជ្ញាធរពង្រឹងទប់ស្កាត់បទល្មើសឆក់ត្រី | |

| | | | | | |
|---|---|---|---|---|---|
| យល់ដឹងពីច្បាប់ និងកាត់បន្ថយទំនាស់ដីធ្លី | | និងកាន់តែប្រសើឡើង ។ | | ផ្សព្វផ្សាយការកាប់រានយកដីព្រៃធ្វើជាកម្មសិទ្ធ | |
| មានសុវត្ថភាពសណ្តាប់ធ្នាប់នៅតាមមូលដ្ឋាន | ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំឯកភាព ស្រុកអូរជុំ ខេត្តរតនគិរី | នៅឆ្នាំ២០០៨ដល់ឆ្នាំ២០១២ប្រជាពលរដ្ឋក្មេងចាស់ប្រុសស្រីមានសុវត្ថភាពសណ្តាប់សន្តិសុខតាមមូលដ្ឋានមានការយល់ដឹងពីច្បាប់ផ្សេងៗកាត់បន្ថយទំនាស់ព្រមទាំងព្រមទាំងការចូលរួមយ៉ាងសកម្ម ដើម្បីថែរក្សាការពារជាពិសេសការប្រើប្រាស់អោយបានសមស្រប និងកាន់តែប្រសើឡើង ។ | ពង្រឹងការងារសន្តិសុខកាត់បន្ថយអំពើចោរកម្មតាមមូលដ្ឋាន ។ | ពង្រឹងការងារសន្តិសុខ និងច្បាប់ចោរកម្ម ។ | |
| បានយល់ដឹងពីតួនាទីកាត់បន្ថយទំនាស់ក្នុងគ្រួសារ<br><br>មានវិជ្ជាជីវៈកើនប្រាក់ | ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំឯកភាព ស្រុកអូរជុំ ខេត្តរតនគិរី | នៅឆ្នាំ២០០៨ដល់ឆ្នាំ២០១២ប្រជាពលរដ្ឋក្មេងចាស់ប្រុសស្រីមានសុភមង្គលក្នុងគ្រួសារតាមរយៈការយលដឹងពី | បង្កើនកាយល់ដឹងពីតួនាទីបុរសស្រ្តី ពីជំនាញវិជ្ជាជីវៈ ពីការជួញដូរមនុស្ស និងកាត់ | ផ្សព្វផ្សាយអំពីតួនាទីបុរសស្រ្តី<br><br>បណ្តុះបណ្តាលវិជ្ជាជីវៈចំរុះដល់ស្រ្តី | |

<table>
<tr><td>ចំណូល</td><td rowspan="2"></td><td rowspan="3">ច្បាប់ជួញដូរស្ត្រីនិងកុមារមានសមភាព និងសមធម៌រវាងបុរសនិងស្ត្រី មានជំនាញវិជ្ជាជីវៈសម្រាប់រកចំនួលក្នុងគ្រួសារ កាត់ បន្ថយអំពើហឹង្សាក្នុងគ្រួសារ ព្រមទាំងការចូលរួមយ៉ាងសកម្មដើម្បីថែរក្សាការពារជាពិសេសការប្រើប្រាស់អោយបានសមស្រប និងកាន់តែប្រសើឡើង ។</td><td rowspan="2">បន្ថយអំពើហឹង្សាក្នុងគ្រួសារ ។</td><td rowspan="2">អប់រំផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រីនិងកុមារ</td><td rowspan="2"></td></tr>
<tr><td>បានយល់ដឹងពីច្បាប់និងទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារ</td></tr>
<tr><td>គ្រួសារមានសុភមង្គល</td><td>ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំឯកភាព ស្រុកអូរជុំ ខេត្តរតនគីរី</td><td>- លើកកំពស់វិស័យអប់រំ</td><td>ផ្សព្វផ្សាយច្បាប់អំពើហឹង្សាក្នុងគ្រួសារ</td><td></td></tr>
</table>

# ឧបសម្ព័ន្ធ ៥

## បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១ [១] | ៥ឆ្នាំទី២ [២] | ៥ឆ្នាំទី៣ [៣] | |
| ២.៦.១. | គំរោងផ្នែកហេដ្ឋរចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. សាងសង់ផ្លូវលំក្រាលគ្រួសក្រហម | | | | | | ១០,០០០ម |
| | ១.១.២. ជួសជុលផ្លូវលំក្រាលគ្រួសក្រហម | | | | | | ១៤,០០០ម |
| | ១.១.៣. សាងសង់ស្ពានឈើ | | | | | | |
| | ១.១.៤. សាងសង់លូកាត់ផ្លូវ | | | | | | |
| | **១.២. ប្រព័ន្ធស្រោចស្រព** | | | | | | |
| | ១.២.១. ជួសជុលទំនប់ទឹក | | | | | | |
| | ១.២.២. ស្តារប្រពន្ឋ័ប្រឡាយឡើងវិញ | | | | | | |

[១] - ៥ឆ្នាំទី១ (២០០៨-២០១២)៖ បញ្ចូលគំរោងទាំងអស់របស់ **CDP** ឆ្នាំ ២០០៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង **CLUP** ផងដែរ (៥ ឆ្នាំទី១)

[២] - ៥ឆ្នាំទី២ (២០១៣-២០១៧)៖ គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្ត (៥ ឆ្នាំទី២)

[៣] - ៥ឆ្នាំទី២ (២០១៨-២០២២)៖ គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្តទៀត (៥ ឆ្នាំទី៣)

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ជីកស្រះចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ | | | | | | |
| | ១.៣.២. សាងសង់មជ្ឈមណ្ឌលវប្បធម៌ជនជាតិដើមភាគតិច | | | | | | |
| | ១.៣.៣. ជួសជុលអណ្តូងខូចខាត | | | | | | |
| | ១.៣.៤. សាងសង់សាលារៀន | | | | | | |
| | ១.៣.៥. ផ្សេងៗ | | | | | | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | | | | | | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | | | | | | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | | | | | | |
| | ២.៦.១.២.៥. ផ្តល់គ្រូគ្រប់កំរិត | | | | | | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២.៦.១.៤. ប៉ុស្តិ៍សុខភាព | | | | | | |
| | ២.៦.១.៥. ប៉ុស្តិ៍សុខភាពតាមភូមិ | | | | | | |
| | ២.៦.១.៦. ផ្តល់ធុងចំរោះទឹកស្អាត | | | | | | |
| | ២.៦.១.៧. អណ្តូងទឹកស្អាតបន្ថែម | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.៨. ផ្តល់បង្គន់អនាម័យ | | | | | | |
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. វគ្គបណ្តុះបណ្តាលការងាររដ្ឋបាលនិង អភិបាលកិច្ចដល់ គ. ផ. ថ | | | | | | |
| | ២.៦.១.៤.២. ទប់ស្កាត់ការហូរចូល នូវគ្រឿងញៀន | | | | | | |
| | ២.៦.១.៤.៣. ពង្រឹងមន្ត្រីប៉ុស្តិ៍រដ្ឋបាលឃុំ | | | | | | |
| | ២.៦.១.៤.៤. ទប់ស្កាត់ការនេសាទខុសច្បាប់ | | | | | | |
| | ២.៦.១.៤.៥. ពង្រឹងប្រព័ន្ធកសាងផែនការតាមមូលដ្ឋាន | | | | | | |
| | **២.៦.១.៥. កន្លែងគោរពបូជា** | | | | | | |
| | ២.៦.១.៥.១. ទីកន្លែងសាការៈបូជា | | | | | | |
| | ២.៦.១.៥.២. វត្តព្រះអារាម | | | | | | |
| | ២.៦.១.៥.៣. សាលាឆទាន | | | | | | |
| | ២.៦.១.៥.៤. សាឡម ជនជាតិ ឥស្លាម | | | | | | |
| ២.៦.២. | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. ដីតំបន់ប្រើប្រាស់ច្រើនយ៉ាង | | | | | | |
| | ២.៦.២.១.២. ដីសម្បទានសង្គមកិច្ច | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |
| | ២.៦.២.២.១. ដីភូមិ | | | | | | |
| | ២.៦.២.២.២. ដីវាលកប់ខ្មោច | | | | | | |
| | ២.៦.២.២.៣. ដីវាលស្រែ | | | | | | |
| | ២.៦.២.២.៤. ដីចំការពនេចរ | | | | | | |
| | ២.៦.២.២.៥. ដីចំការដំណាំរយៈពេលខ្លី | | | | | | |
| | ២.៦.២.២.៦. ដីចំការដំណាំឈើហូបផ្លែ | | | | | | |
| | ២.៦.២.២.៧. ផ្សេងៗ | | | | | | |
| | **២.៦.២.៣. គំរោងផ្នែកបង្កើនជំនាញ និងមុខរបរ** | | | | | | |
| | ២.៦.២.៣.១. វគ្គបណ្តុះបណ្តាលអំពីការធ្វើស្រែបង្កើនរដូវ | | | | | | |
| | ២.៦.២.៣.២. វគ្គបណ្តុះបណ្តាល អំពីការប្រើប្រាស់ដីធម្មជាតិ | | | | | | |
| | ២.៦.២.៣.៣. ផ្សព្វផ្សាយពីច្បាប់ជលផល | | | | | | |
| | ២.៦.២.៣.៤. បង្កើតគណៈកម្មាការគ្រប់គ្រងជលផល | | | | | | |
| | | | | | | | |